អង្គការសហប្រជាជាតិ

A/68/299

# អគ្គលេខាធិការ

ចែកចាយ៖ ទូទៅ
៧ សីហា ២០១៣

ឯកសារដើម៖ អង់គ្លេស

សម័យប្រជុំលើកទីហុកសិបប្រាំបី

ចំណុច ៦៩(ខ) នៃរបៀបវារៈបណ្ដោះអាសន្ន *

*ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស៖ បញ្ហាសិទ្ធិមនុស្ស រាប់ទាំងវិធីសាស្ត្រតាមជម្រើសផ្សេង សម្រាប់កែលំអការទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព*

# សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម

## សេចក្ដីកំណត់ដោយអគ្គលេខាធិការ

អគ្គលេខាធិការ មានកិត្តិយសសូមបញ្ជូនទៅសមាជិករបស់មហាសន្និបាត នូវរបាយការណ៍របស់អ្នករាយការណ៍ពិសេស ស្ដីពី សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និង សមាគម គឺលោក **ម៉ៃណា គីអាយ** (Maina Kiai) ដែលបានដាក់ជូនអនុលោមតាមសេចក្តីសម្រេចលេខ ២១/១៦ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

* A/68/150.

13-42309 (E)    120913

Please recycle

# របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពី សិទ្ធិសេរីភាពក្នុង ការជួបប្រជុំដោយសន្តិវិធី និងសមាគម


## សេចក្តីសង្ខេប

របាយការណ៍នេះ គឺជារបាយការណ៍ដំបូងរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម ដាក់ជូនមហាសន្និបាត។ របាយការណ៍នេះនិយាយពីកង្វល់អំពីការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគមក្នុងបរិបទនៃការបោះឆ្នោត។ អ្នករាយការណ៍ពិសេសមានកង្វល់ជាខ្លាំងអំពីការរំលោភ និងការបំពានសិទ្ធិមនុស្សកាន់តែកើនឡើង ដែលបាននឹងកំពុងប្រព្រឹត្តនៅក្នុងតំបន់ជាច្រើននៃពិភពលោក ប្រឆាំងនឹងបុគ្គលទាំងឡាយដែលប្រើប្រាស់ ឬស្វែងរកការប្រើប្រាស់សិទ្ធិបែបនេះនៅក្នុងបរិបទនៃការបោះឆ្នោត និងដែលធ្វើអោយខូចខាតដល់ការបោះឆ្នោតបែបនេះជានិរន្តរ៍។

# I. សេចក្តីផ្តើម

១. អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ១៥/២១សម្រាប់រយៈពេលបីឆ្នាំដំបូង។ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងលោក **ម៉ៃណា គីអាយ** (Maina Kiai) ជាអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម ក្នុងខែមីនា ឆ្នាំ២០១១ ដោយចាប់ផ្តើមពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១។ របាយការណ៍នេះគឺជារបាយការណ៍ដំបូងដែលបានដាក់ជូនមហាសន្និបាតដោយអ្នករាយការណ៍ពិសេសរូបនេះ តបតាមការស្នើសុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស តាមសេចក្តីសម្រេចរបស់ខ្លួនលេខ២១/១៦ ដែលថារបាយការណ៍ប្រចាំឆ្នាំត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ។ របាយការណ៍នេះ លើកពីកង្វល់អំពីការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគម នៅក្នុងបរិបទនៃការបោះឆ្នោត និងគួរត្រូវបានអានជាមួយរបាយការណ៍តាមប្រធានបទលេខ (A/HRC/20/27 និងA/HRC/23/39) របស់អ្នករាយការណ៍ពិសេស ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។

២. រៀងរាល់ឆ្នាំ ការបោះឆ្នោត ប្រជាសិទ្ធិ និងប្រជាមតិត្រូវបានធ្វើឡើងនៅកម្រិតផ្សេងៗគ្នា រាប់ទាំងនៅកម្រិតប្រធានាធិបតី នីតិបញ្ញត្តិ និងនៅថ្នាក់មូលដ្ឋាន នៅតាមប្រទេសជាច្រើន។ ការប្រកួតប្រជែងកម្រិតខ្ពស់ដែលមានក្នុងការបោះឆ្នោតភាគច្រើនត្រូវបានឃើញថាមានការរំលោភសិទ្ធិមនុស្សដែលមានការរីករាលដាល រួមទាំងសិទ្ធិរស់រានមានជីវិត សេរីភាពនៃការបញ្ចេញមតិ សេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសេរីភាពសមាគម។ បើតាមទស្សនៈរបស់អ្នករាយការណ៍ពិសេស សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគម បានស្ថិតក្រោមការវាយប្រហារកាន់តែខ្លាំងឡើងដោយសាររបបបច្ចុប្បន្នឬរបបខាងមុខស្វះស្វែងដើម្បីរក្សា ឬទទួលបានអំណាចតាមគ្រប់មធ្យោបាយ។ អ្នករាយការណ៍ពិសេសជឿជាក់ថា បរិបទនៃការបោះឆ្នោតសមនឹងទទួលបានការយកចិត្តទុកដាក់ពិសេស ដោយសារតែលទ្ធភាពរបស់បុគ្គលនិងសមាគម ក្នុងការបង្កើត និងប្រតិបត្តិការដោយសេរី ត្រូវប្រឈមនឹងហានិភ័យ ជាពិសេសក្នុងអំឡុងពេលនោះ។ អ្នករាយការណ៍ពិសេស ត្រូវបានបញ្ចុះបញ្ចូលឲ្យធ្វើការសន្និដ្ឋាន ដែលជាលទ្ធផលនៃបណ្តឹងដែលលោកបានទទួល កំពុងតែកើនឡើងទាក់ទងនឹងការយាយី ការបំភិតបំភ័យ និងការរឹតត្បិតមិនសមហេតុផល ទៅលើបុគ្គល សមាគម និងសមាជិកសមាគម នៅមុនពេល ឬនៅបន្ទាប់ពីការបោះឆ្នោតប្រកួតប្រជែងគ្នា។

៣. នៅពេលសរសេររបាយការណ៍នេះ អ្នករាយការណ៍ពិសេសទទួលប្រយោជន៍យ៉ាងច្រើនពីការចូលរួមនៅក្នុងកិច្ចប្រជុំអ្នកជំនាញ រយៈពេលមួយថ្ងៃ ដែលបានធ្វើឡើងនៅទីក្រុងហ្សឺណែវ កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣។ អ្នករាយការណ៍ពិសេសសូមថ្លែងអំណរគុណដល់អ្នកទាំងឡាយដែលបានចូលរួមរៀបចំកិច្ចប្រជុំនេះ និងដល់អ្នកដែលបានចែករំលែកបទពិសោធន៍របស់ខ្លួន ដើម្បីផ្តល់ជាព័ត៌មានដល់របាយការណ៍នេះ ទាំងនៅក្នុងកិច្ចប្រជុំនោះ ទាំងនៅក្នុងវេទិកាផ្សេងៗទៀត។ អ្នករាយការណ៍ពិសេសក៏បានពិចារណាផងដែរ អំពីកត្តាពាក់ព័ន្ធនៃការងារដែលអាចមានស្រាប់នៅក្នុងក្រុមប្រឹក្សា។[9] ស្ថានភាពរបស់ប្រទេសដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ត្រូវបានក្លាយជាប្រធានបទនៃលិខិតទាក់ទង ផ្ញើទៅរដ្ឋាភិបាល ក៏ដូចជាសេចក្តីប្រកាសព័ត៌មាន និងរបាយការណ៍ដែលចេញដោយអ្នកកាន់អាណត្តិតាមនីតិវិធីពិសេស និងមន្ត្រីជាន់ខ្ពស់អង្គការសហប្រជាជាតិ។

## II. សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម គឺជាផ្នែកស្នូលក្នុងការបោះឆ្នោតដោយសេរី និងយុត្តិធម៌

### *ក. លទ្ធិប្រជាធិបតេយ្យ និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម*

៤. លទ្ធិប្រជាធិបតេយ្យ ជាប្រព័ន្ធមួយដែលប្រជាពលរដ្ឋចូលរួមដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការដឹកនាំកិច្ចការសាធារណៈ មានការយកចិត្តទុកដាក់ដ៏ទូលំទូលាយនៅទូទាំងពិភពលោក។ ការបោះឆ្នោត ការធ្វើប្រជាមតិ និងការធ្វើប្រជាសិទ្ធិ ដែលតាមរយៈនេះប្រជាពលរដ្ឋជ្រើសរើសតំណាងរបស់ខ្លួន និងបង្ហាញជម្រើសរបស់ខ្លួនអំពីច្បាប់ ឬគោលនយោបាយផ្សេងៗ មានអនុវត្តនៅប្រទេសភាគច្រើនលើពិភពលោក។ ដូចមានចែងក្នុងមាត្រា២១(៣) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យគឺជាដំណើរការមួយដែលក្នុងនោះ "ឆន្ទៈរបស់ប្រជាពលរដ្ឋត្រូវតែជាមូលដ្ឋានគ្រឹះនៃអំណាចរបស់រដ្ឋាភិបាល"។ ជាទូទៅ ឆន្ទៈនេះនឹងត្រូវបានសម្តែងចេញតាមរយៈការបោះឆ្នោតយ៉ាងទៀងទាត់តាមកាលកំណត់ ដោយសេរី និងមានការប្រកួតប្រជែងគ្នា ដើម្បីសម្រេចអំពីគោលនយោបាយដោយផ្ទាល់ឬដោយប្រយោល តាមរយៈតំណាងដែលបានជ្រើសរើសដែលត្រូវតែមានគណនេយ្យភាពចំពោះម្ចាស់ឆ្នោតរបស់ខ្លួន។

[9] ដោយរួមទាំងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅបេឡារុស ដែលផ្តោតទៅលើកិច្ចការសិទ្ធិមនុស្សនៅក្នុងដំណើរការបោះឆ្នោត (A/68/276)។.

ម្យ៉ាងវិញទៀត ប្រជាធិបតេយ្យដូចបានឆ្លុះបញ្ចាំងនៅក្នុងដំណើរការបោះឆ្នោត ជាទូទៅពាក់ព័ន្ធនឹងការប្រើប្រាស់ដំណើរការច្បាស់លាស់ ដែលអាចព្យាករណ៍បាន ជាមួយនឹងលទ្ធផលមិនច្បាស់លាស់ ចំណែកឯប្រព័ន្ធមិនប្រជាធិបតេយ្យវិញ អាចកំណត់បានតាមរយៈការដែលថា ដំណើរការបោះឆ្នោតទាំងមូល ត្រូវបានបង្ហាញឲ្យឃើញពីដំណើរការមិនប្រាកដប្រជា និងមិនច្បាស់លាស់ ប៉ុន្តែលទ្ធផលរបស់វាអាចព្យាករណ៍បានទៅវិញ។ ទោះជាយ៉ាងណាក៏ដោយ គុណភាពនៃការបោះឆ្នោតត្រូវស្ថិតក្រោមការពិនិត្យពិច័យកាន់តែខ្លាំងឡើងៗ ដើម្បីធានាថាលទ្ធផលនៃការបោះឆ្នោតគឺតំណាងឲ្យឆន្ទៈរបស់ប្រជាពលរដ្ឋ។ ការបោះឆ្នោតផ្តល់ភាពស្របច្បាប់ដល់រដ្ឋាភិបាល ប្រសិនជាការបោះឆ្នោតនោះ មិនត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីឆន្ទៈរបស់ប្រជាពលរដ្ឋទេ នោះការមិនសប្បាយចិត្ត និងការដកហូតសិទ្ធិបោះឆ្នោត អាចបង្កឱ្យមានជម្លោះ ហើយពេលខ្លះអាចបង្កឲ្យមានជម្លោះហិង្សាក៏សឹងមាន។ ដើម្បីរក្សាបាននូវឧត្តមគតិប្រជាធិបតេយ្យ ជាការចាំបាច់សំរាប់របបនានា គឺត្រូវប្រកាន់ខ្ជាប់នូវនីតិរដ្ឋ គោរព និងការពារសិទ្ធិមនុស្ស និងរក្សាស្មារតីប្រុងប្រយ័ត្ន និងឆ្លើយតបចំពោះទស្សនៈ និងគំនិតរបស់ប្រជាពលរដ្ឋនៅគ្រប់ពេលវេលា។

៥. សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគម មានភាពពាក់ព័ន្ធទៅនឹងដំណើរការប្រជាធិបតេយ្យ ទាំងនៅក្នុងអំឡុងពេលនៃការបោះឆ្នោត ទាំងនៅចន្លោះពេលនៃការបោះឆ្នោត។ អ្នករាយការណ៍ពិសេសគូសបញ្ជាក់ឡើងវិញថា សិទ្ធិទាំងនេះ គឺជាសមាសភាគដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ព្រោះថាវាផ្តល់សិទ្ធិអំណាចដល់ស្ត្រី បុរស និងយុវជន "ឱ្យសម្តែងទស្សនៈនយោបាយរបស់ខ្លួន ចូលរួមក្នុងការកំសាន្តសិល្បៈ និងអក្សរសាស្ត្រ និងសកម្មភាពផ្សេងៗទៀតខាងវប្បធម៌ សង្គម និងសេដ្ឋកិច្ច ចូលរួមក្នុងការគោរពប្រតិបត្តិសាសនាឬជំនឿផ្សេងៗ បង្កើតនិងចូលរួមក្នុងសហជីពនិងសហករណ៍ និងបោះឆ្នោតជ្រើសតាំងអ្នកដឹកនាំដើម្បីតំណាងឲ្យផលប្រយោជន៍របស់ខ្លួន និងឲ្យពួកគេមានគណនេយ្យភាព" (បុព្វកថានៃសេចក្តីសម្រេចលេខ១៥/២១របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស)។

៦. ពិសេសជាងនេះទៀត សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម គឺជាមធ្យោបាយដ៏សំខាន់មួយសម្រាប់បុគ្គលនិងក្រុមបុគ្គល ចូលរួមក្នុងកិច្ចការសាធារណៈ។ ការអនុវត្តសិទ្ធិទាំងនេះ ផ្តល់ជាមធ្យោបាយមួយ ដែលតាមរយៈនោះ ប្រជាពលរដ្ឋអាចចងក្រង និងសម្តែងកង្វល់ និងចំណាប់អារម្មណ៍របស់ខ្លួន និងខិតខំប្រឹងប្រែងដើម្បីធ្វើជាគំរូដល់អភិបាលកិច្ចដែលឆ្លើយតបទៅនឹងបញ្ហារបស់ពួកគេ។ តួយ៉ាង សិទ្ធិនេះមានសារៈសំខាន់ដល់សកម្មភាពអប់រំអ្នកបោះឆ្នោត បោះឆ្នោត សង្កេតការណ៍ និងតាមឃ្លាំមើលការបោះឆ្នោត និងដាក់ឲ្យបេក្ខជនឈរឈ្មោះបោះឆ្នោត និងមន្ត្រីជាប់ឆ្នោតមានគណនេយ្យភាព។

៧. ច្បាប់អន្តរជាតិមានចែងពីគោលការណ៍ និងបទដ្ឋានអំពីដំណើរការ និងលទ្ធផលនៃការបោះឆ្នោតអាចត្រូវបានវាស់វែងបាន។ ការវាយតំលៃដែលជិតមកដល់ ដោយទទួលស្គាល់ថារដ្ឋនានាបានទទួលយកការប្តេជ្ញាចិត្តតាមផ្លូវច្បាប់ដ៏ជាក់លាក់ និងថាការបោះឆ្នោតដែលខ្លួនរៀបចំឡើងគួរបំពេញតាមការប្តេជ្ញាចិត្តនោះ ផ្តល់ជាស្តង់ដារឯកភាពតែមួយ និងជាសត្យានុម័តដល់ការសង្កេតការណ៍នៃការបោះឆ្នោត។ សកលភាព ភាពទាក់ទងគ្នាទៅមក និងភាពអាស្រ័យគ្នាទៅមកនៃសិទ្ធិមនុស្ស ត្រូវបានអនុវត្តដោយរដ្ឋនានាដែលមានការទទួលខុសត្រូវធានាពីការអនុវត្តនៃសិទ្ធិទាំងអស់ ក្នុងកំឡុងពេលដំណើរការបោះឆ្នោត ដើម្បីសម្រេចបានលទ្ធផលជាវិជ្ជមាន។ ការអនុវត្តដូចនេះទទួលស្គាល់ថា ដំណើរការបោះឆ្នោតដ៏ជោគជ័យមួយ ត្រូវទៅហួសពីព្រឹត្តិការណ៍នៃថ្ងៃបោះឆ្នោត។ ក្របខ័ណ្ឌច្បាប់ បរិយាកាសនយោបាយ សមត្ថភាពស្ថាប័នទាំងមុនពេល កំឡុងពេល និងក្រោយថ្ងៃបោះឆ្នោត សុទ្ធតែមានឥទ្ធិពលទៅលើការអនុវត្តសិទ្ធិ។ លើសពីនេះ អ្នករាយការណ៍ពិសេសជឿជាក់ថា ដំណើរការបោះឆ្នោត មិនអាចត្រូវទុកជាសេរីឬត្រឹមត្រូវនោះទេ ហើយហេតុដូច្នេះ លទ្ធផលក៏មិនគួរចាត់ទុកជាលទ្ធផលនៃការបោះឆ្នោតដ៏ពិតប្រាកដមួយ ដូចដែលតម្រូវតាមច្បាប់អន្តរជាតិនោះដែរ ប្រសិនបើមានឧបសគ្គដែលរីករាលដាលជាប្រព័ន្ធ ដល់ការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម។

៨. ការរក្សាសន្តិភាព ក្នុងកំឡុងពេលដំណើរការនៃបោះឆ្នោត គឺជាការចាំបាច់ដល់អ្នកបោះឆ្នោតទាំងអស់ឱ្យចេញទៅបោះឆ្នោត និងអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន។ ទោះបីយ៉ាងណាក៏ដោយ ទោះជា[ការរិតត្បិតនោះ]សំខាន់ ក៏វាមិនត្រូវផ្តល់យុត្តិកម្មឱ្យបន្តអនុវត្តមិនល្អដល់ការបោះឆ្នោត និងការដាក់កំហិតមិនសមហេតុផលដល់សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម ឬសិទ្ធិដទៃទៀតដែរ តួយ៉ាងបំរាមគ្មានដែនកំណត់ និងមិនអាចគ្រប់គ្រងបានដល់ការតវ៉ា ឬបាតុកម្មប្រឆាំងនឹងលទ្ធផលនៃការបោះឆ្នោត។ នៅទីណាដែលសិទ្ធិទាំងនេះត្រូវបានបំពាន ទោះនៅដំណាក់កាលណាក៏ដោយ ក្នុងកំឡុងពេលដំណើរការនៃការបោះឆ្នោតគួរមានដំណោះស្រាយភ្លាម និងមានប្រសិទ្ធភាព ដោយអាជ្ញាកណ្តាលមួយដែលមិនលំអៀង។

៩. នៅក្នុងរបាយការណ៍នេះ អ្នករាយការណ៍ពិសេសផ្តោតយ៉ាងទូលាយទៅលើតួនាទីរបស់សមាគម រួមទាំងគណៈបក្សនយោបាយ ថាជាយានស្នូលដែលបុគ្គលនានា អាចចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈដោយសន្តិវិធីតាមរយៈតំណាងដែលបានជ្រើសរើស។ គណៈបក្សនយោបាយដើរតួនាទីយ៉ាងសំខាន់ "ក្នុងការធានាពហុនិយម និងការប្រព្រឹត្តទៅដ៏ត្រឹម

ត្រូវនៃលទ្ធិប្រជាធិបតេយ្យ”។[២] របាយការណ៍នេះអនុម័តនិយមន័យនៃគណៈបក្សនយោបាយថាជា "សមាគមសេរីរបស់មនុស្ស មានគោលដៅមួយក្នុងចំណោមគោលដៅនានានោះគឺចូលរួមក្នុងការគ្រប់គ្រងកិច្ចការសាធារណៈ រួមទាំងតាមរយៈការបង្ហាញបេក្ខជនឈរឈ្មោះបោះឆ្នោតដោយសេរីនិងប្រជាធិបតេយ្យ។[៣] ប្រការដែលសំខាន់នោះ គឺគណៈបក្សនយោបាយមួយ ជា"សមាគម" មួយ(A/HRC/20/27, កថាខ័ណ្ឌទី៥១-៥២), ទោះបីជាវាមានលក្ខណៈពិសេសដែលអាចបញ្ញត្តិដោយច្បាប់ដោយឡែក និងស្ថិតនៅក្រោមវិធាននានាផ្សេងពីវិធានទាំងឡាយសំរាប់សមាគមក៏ដោយ។ អ្នករាយការណ៍ពិសេសចាត់ទុកភាពខុសខុសគ្នាជាចំបងរវាងគណៈបក្សនយោបាយ និងសមាគម ត្រង់លទ្ធភាពរបស់គណៈបក្សនយោបាយបង្ហាញបេក្ខជននានាសំរាប់ការបោះឆ្នោត ហើយបន្ទាប់មក គឺដើម្បីបង្កើតរដ្ឋាភិបាល ដែលបេក្ខជនទាំងនោះត្រូវឈ្នះក្នុងការបោះឆ្នោតដ៏ពិតប្រាកដមួយ។ ហេតុដូច្នេះលោកគូសបញ្ជាក់ថា ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការបោះឆ្នោត មិនគួរនាំឱ្យមានការលាបពណ៌ពួកគេដោយមិនស្មគ្រចិត្ត ឬចាត់ទុកពួកគេថាជាគណៈបក្សនយោបាយ ដោយសារតែការចូលរួមរបស់ពួកគេនៅក្នុងជីវភាពសាធារណៈ តាមមធ្យោបាយមួយដែលពួកគេបានជ្រើសរើសនោះទេ។

**១០.** ខណៈដែលមានតែអង្គការសង្គមស៊ីវិលមួយចំនួន អាចធ្វើការដោយផ្ទាល់លើបញ្ហាពាក់ព័ន្ធនឹងការបោះឆ្នោត ដូចជាការអប់រំអ្នកបោះឆ្នោត ការសង្កេតការណ៍បោះឆ្នោត កំណែទម្រង់ស្ថាប័នបោះឆ្នោត និងគណនេយ្យភាពរបស់បេក្ខជន និងមន្ត្រីដែលត្រូវជាប់ឆ្នោត អ្នករាយការណ៍ពិសេសទទួលស្គាល់ដែរថា កំឡុងពេលបោះឆ្នោតផ្តល់ឱកាសបឋមដល់អង្គការសង្គមស៊ីវិលជាច្រើនចូលរួមជាមួយអ្នកតំណាងដែលនឹងត្រូវជាប់ឆ្នោត គូសបញ្ជាក់ពីកង្វល់និងផលប្រយោជន៍របស់ពួកគេ ដើម្បីទទួលបានចម្លើយតបគោលនយោបាយ និងជាទូទៅប្រើប្រាស់សិទ្ធិរបស់ពួកគេដើម្បីចូលរួមក្នុងកិច្ចការសាធារណៈ។ ដោយសារតែហេតុផលនេះ កិច្ចពិភាក្សាណាមួយអំពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំនិងសមាគមនៅក្នុងបរិបទនៃការបោះឆ្នោត ត្រូវរាប់បញ្ចូលគ្រប់អង្គការសង្គមស៊ីវិល ដោយមិនគិតពីវិស័យគោលដៅនានារបស់ពួកគេឡើយ។

[២] តុលាការសិទ្ធិមនុស្សអឺរ៉ុប គណៈបក្សសហភាពកុំមុយនីសទួគីនិងគណៈបក្សដទៃទៀត ប្រឆាំងនឹងប្រទេសទួគី។ សេចក្តីអនុវត្តលេខ២០/១៩៩៧/៨០៤/១០០៧ ចុះថ្ងៃទី២៥ ឧសភា ១៩៩៨ វក្យខ័ណ្ឌទី៤១។

[៣] អង្គការសន្តិសុខ និងសហប្រតិបត្តិការអឺរ៉ុប(OSCE)/ការិយាល័យសិទ្ធិមនុស្សនិងស្ថាប័នប្រជាធិបតេយ្យ និងគណៈកម្មការទីក្រុងវីនីស។គោលការណ៍ណែនាំស្តីពីវិធានសំរាប់គណៈបក្សនយោបាយ(វ៉ាសូវី/ស្ត្រាបួរ២០១១)វក្យខ័ណ្ឌ៩

១១. ពាក្យ"ការបោះឆ្នោត" ដូចបានប្រើនៅក្នុងរបាយការណ៍នេះ រួមទាំងការបោះឆ្នោតទាំងឡាយដែលរៀបចំឡើងដើម្បីជ្រើសរើសប្រធានាធិបតី នីតិបញ្ញត្តិ និងអ្នកតំណាងរដ្ឋបាលនៅមូលដ្ឋាន ការរៀបចំប្រជាសិទ្ធិ និងប្រជាមតិ។ រយៈពេលបោះឆ្នោតមិនតែងតែឆ្លើយតបទៅនឹងការកំណត់ពេលដ៏ត្រឹមត្រូវនោះទេ។ ជាការពិត អាចអះអាងបានថា ការបញ្ចប់រយៈពេលបោះឆ្នោតមួយ ក្នុងកំរិតមួយដែលអាចកំណត់បាន ជាសញ្ញាចាប់ផ្តើមនៃការបោះឆ្នោតបន្ទាប់។ ព្រឹត្តិការណ៍ខ្លះនៅក្នុងដំណើរការបោះឆ្នោត អាចកំណត់ពីការលៃពេលវេលាជាក់លាក់បាន តួយ៉ាងការអប់រំអ្នកបោះឆ្នោត រយៈពេលយុទ្ធនាការ ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ទោះបីយ៉ាងណាក៏ដោយ សកម្មភាពដទៃទៀតដែលពាក់ព័ន្ធដល់ដំណើរការ អាចនៅតែបន្ត ក្នុងរយៈពេលយូរក្រោយពីបោះឆ្នោត ដូចជាការកែទម្រង់ច្បាប់ និងពង្រឹងស្ថាប័នជាដើម។ តាមរយៈការធ្វើអធិប្បាយពីវិសាលភាពនៃរបាយការណ៍នេះ ដែលគ្របដណ្តប់លើរយៈពេលមុនការបោះឆ្នោត កំឡុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នករាយការណ៍ពិសេសសូមផ្តាំផ្ញើថា បរិបទនៃការបោះឆ្នោត គឺមិនសំដៅតែលើព្រឹត្តិការណ៍ជាក់លាក់មួយ ឬពេលវេលាដោយឡែកណាមួយនោះទេ ឧទាហរណ៍ថ្ងៃបោះឆ្នោត ទោះបីជាការគូសសន្លឹកឆ្នោតរបស់នរណាម្នាក់ គឺជាពេលវេលាសំខាន់បំផុតនៃការបោះឆ្នោតក៏ដោយ។ អ្នករាយការណ៍ពិសេសកត់សំគាល់ថា ការបោះឆ្នោតតែងតែជាការប្រកួតប្រជែងដ៏ក្តៅគគុកដែលជាហានិភ័យយ៉ាងច្រើនសំរាប់អាជ្ញាធរ និងអ្នកបោះឆ្នោត។ នៅក្នុងបរិបទនេះ រដ្ឋមានកាតព្វកិច្ចគោរព និងសម្រួលដល់សិទ្ធិសេរីភាពក្នុងការជួបប្រជុំនិងសមាគម នៅក្នុងដំណើរការនៃការបោះឆ្នោតទាំងស្រុង។

## *ខ. ក្របខ័ណ្ឌច្បាប់អន្តរជាតិ ទាក់ទងនឹងសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម នៅក្នុងបរិបទនៃការបោះឆ្នោត*

១២. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ១៥/២១ ក្រុមប្រឹក្សាសិទ្ធិមនុស្សសូមអំពាវនាវដល់រដ្ឋនានា ឱ្យគោរពនិងការពារយ៉ាងពេញលេញដល់សិទ្ធិរបស់បុគ្គលទាំងអស់ក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគមដោយសេរី រួមទាំងនៅក្នុងបរិបទនៃការបោះឆ្នោត។ បន្ថែមពីលើសញ្ញាណនៃប្រជាធិបតេយ្យ សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម ត្រូវបានអនុវត្តដោយស្មៀមស្ងាត់ពីសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលនៃប្រទេសមួយ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងមាត្រា២១ (៣)ថា "ឆន្ទៈរបស់ប្រជាពលរដ្ឋគឺជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាល។ ឆន្ទៈនេះត្រូវបាន

សំដែងតាមរយៈការបោះឆ្នោតទៀងទាត់ និងពិតប្រាកដ ដែល ការបោះឆ្នោតនេះត្រូវរៀបចំជាសកល និងស្មើភាព និងត្រូវធ្វើជាសំងាត់ ឬសមមូលនឹងនីតិវិធីបោះឆ្នោតដោយសេរី"។ ដូចគ្នានេះដែរ មាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គូសបញ្ជាក់ពីសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូប ដោយគ្មានការបែងចែក និងការរិតត្បិតដែលមិនសមហេតុផលៈ (ក)ចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនបានជ្រើសរើសដោយសេរី។ (ខ)បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតនៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ ជាសកល ស្មើភាព និងដោយសម្ងាត់ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈរបស់អ្នកបោះឆ្នោត។ និង (គ) តាមអត្ថន័យទូទៅនៃពាក្យសមភាព មានសិទ្ធិប្រើប្រាស់សេវាសាធារណៈនៅក្នុងប្រទេសរបស់ខ្លួន។[៤] គណៈកម្មាធិការសិទ្ធិមនុស្សទទួលស្គាល់ថា ការទទួលបានពេញលេញនូវសិទ្ធិទាំងនេះ អាស្រ័យលើទំនាក់ទំនងព័ត៌មាន និងគំនិតដោយសេរីអំពីបញ្ហានយោបាយ និងសាធារណៈ រវាងប្រជាពលរដ្ឋបេក្ខជន និងតំណាងជាប់ឆ្នោត ដែលតម្រូវឱ្យមានការប្រើប្រាស់សិទ្ធិក្នុងការជួបប្រជុំ និងសមាគមដោយសេរី ក្នុងចំណោមសិទ្ធិដទៃទៀត (សេចក្តីពន្យល់ទូទៅលេខ២៥ កថាខ័ណ្ឌទី២៥)។ ក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ៥៩/២០១ មហាសន្និបាតបានប្រកាសថាសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនិងសមាគម គឺជាធាតុផ្សំយ៉ាងសំខាន់នៃលទ្ធិប្រជាធិបតេយ្យរួមជាមួយសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត នៅក្នុងការបោះឆ្នោតសេរី ពិតប្រាកដតាមកាលកំណត់ និងលើកទឹកចិត្តឱ្យពង្រឹងប្រព័ន្ធគណៈបក្សនយោបាយ និងអង្គការសង្គមស៊ីវិល។

**១៣.** ចំណុចកណ្តាលនៃសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម នៅក្នុងបរិបទនៃការបោះឆ្នោតត្រូវបានបញ្ជាក់នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនិងតំបន់ដទៃផ្សេងៗគ្នា[៥] ជាមួយនឹងស្ថាប័នសន្ធិសញ្ញាទាំងនោះផង។[៦] រដ្ឋសមាជិកនៃសហព័ន្ធអាហ្វ្រិច

[៤] សូមមើលផងដែរមាត្រា៧ នៃអនុសញ្ញាស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ មាត្រា២៩ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ មាត្រា២៣(១)(ខ) នៃអនុសញ្ញាអាមេរិចស្តីពីសិទ្ធិមនុស្ស មាត្រា១៣ នៃធម្មនុញ្ញអាហ្វ្រិចស្តីពីសិទ្ធិមនុស្ស និងប្រជាជន មាត្រា៣៣ នៃធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្ស និងកថាខ័ណ្ឌទី២៥ នៃសេចក្តីប្រកាសសិទ្ធិមនុស្សរបស់សមាគមជាតិអាស៊ីអគ្នេយ៍។

[៥] ជាឧទាហរណ៍ សូមមើលមាត្រា៧(ខ)នៃអនុសញ្ញាស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងមាត្រា២៩(ខ)(១)នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

[៦] សេចក្តីប្រកាសស្តីពីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ អនុម័តដោយក្រុមប្រឹក្សាអន្តរសភា ក្នុងសម័យប្រជុំលើកទី១៥៤របស់ខ្លួន (ទីក្រុងប៉ារីស ២៦ មីនា ១៩៩៤)។

នៅក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍គ្រប់គ្រងការបោះឆ្នោតប្រជាធិបតេយ្យនៅអាហ្វ្រិច (ផ្នែកទី៣-ឃ) បានប្តេជ្ញាចិត្តរៀងៗខ្លួនយ៉ាងជាក់ច្បាស់ក្នុងការការពារសេរីភាពមនុស្ស និង ពលរដ្ឋរបស់ប្រជាពលរដ្ឋទាំងអស់ រួមទាំងសេរីភាពក្នុងការដើរហើរ ការជួបប្រជុំ សមាគម ការសំដែងមតិ និងយុទ្ធនាការ ព្រមទាំងសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមចំណែករបស់ អ្នកពាក់ព័ន្ធទាំងអស់ ក្នុងកំឡុងដំណើរការបោះឆ្នោត។ តាមឯកសារទីក្រុងកូប៉ង់ហាក់[៧] ដែលគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋសមាជិកនៅក្នុងវិស័យបោះឆ្នោត អង្គការសន្តិសុខ និងសហប្រតិបត្តិការអឺរ៉ុប ធានាការពារសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគម (កថាខ័ណ្ឌទី៩.២ និង៩.៣)។ ទោះបីជាលិខិតុបករណ៍តំបន់ដទៃទៀតស្តីពីលទ្ធិប្រជាធិបតេយ្យ មិនមានយោងយ៉ាងជាក់ច្បាស់ដល់សិទ្ធិសេរីភាពសមាគម ក៏លិខិតុបករណ៍ទាំងនេះ ទទួលស្គាល់ថាគណៈបក្សនយោបាយ និងទម្រង់ដទៃទៀតនៃសមាគម គឺជាសមាសភាគយ៉ាងសំខាន់ដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យ។[៨]

**១៤.** ប្រភេទនៃលិខិតុបករណ៍ដែលទទួលស្គាល់ដោយស្ងៀមស្ងាត់ ឬដោយចំហរពីលទ្ធភាពរបស់គណៈបក្សនយោបាយ និងទម្រង់ដទៃទៀតនៃសមាគម ឱ្យបង្កើត និងប្រតិបត្តិនៅក្នុងបរិបទនៃការបោះឆ្នោត ឬទូទៅជាងនេះ នៅក្នុងលទ្ធិប្រជាធិបតេយ្យ គឺជាសូចនាករមួយនៃការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ យ៉ាងហោចណាស់ នៅត្រឹមកំរិតស្តង់ដារកំណត់១ នៅជុំវិញចំណុចកណ្តាលនៃសិទ្ធិទាំងនេះ។ បទពិសោធន៍របស់អ្នករាយការណ៍ពិសេសអំពីការអនុវត្តនៃសិទ្ធិទាំងនេះ មានសុទិដ្ឋិនិយមតិចតួច។ នៅក្នុងបរិបទនៃការបោះឆ្នោត លោកកត់សំគាល់ថា សិទ្ធិនានាអាចងាយរងការរិតត្បិត ហេតុដូច្នេះហើយ លោកទទូចឱ្យប្រកាន់ខ្ជាប់យ៉ាងតឹងរឹងនូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ទោះបីជាសេរីភាព គឺជាវិធាន ហើយការរិតត្បិតគឺជាករណីលើកលែង(A/HRC/20/27 កថាខ័ណ្ឌទី១៦ និងA/HRC/23/39 កថាខ័ណ្ឌ ១៨)អ្នករាយការណ៍ពិសេសសំដែងការសោកស្តាយការពិតដែលថានៅក្នុងករណីភាគច្រើន ការរិតត្បិតមានបំណងទប់ការរិះគន់ ហើយមិនអនុវត្តតាមច្បាប់អន្តរជាតិ គឺថាត្រូវចែងដោយច្បាប់ និងត្រូវតែចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យតាមប្រយោជន៍ដូចមានចែងក្នុងមាត្រា ២១ និង២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[៩]

---

[៧] ឯកសារនេះ អាចរកបានតាមគេហទំព័រនេះ៖ www.osce.org/odihr/elections/14304.

[៨] ធម្មនុញ្ញអាហ្វ្រិចស្តីពីលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងអភិបាលកិច្ច មាត្រា៣និង១២ ធម្មនុញ្ញប្រជាធិបតេយ្យអន្តរអាមេរិច មាត្រា៥ និង២៧។

[៩] សំរាប់ការវិភាគពីការរិតត្បិតដែលអាចអនុញ្ញាតឱ្យបាន សូមមើល A/HRC/20/27, កថាខ័ណ្ឌទ១៥-១៧

១៥. សារសំខាន់នៃការការពារស្មើភាពគ្នានៃសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសមាគម សំរាប់ទាំងអស់គ្នានៅក្នុងបរិបទនៃការបោះឆ្នោត ត្រូវបានលើកកំពស់ដោយសារតែជាសក្តានុពលដល់ភាពងាយរងគ្រោះឱ្យកាន់តែធ្ងន់ធ្ងរឡើង ក្នុងកំឡុងពេលនេះ។ អ្នករាយការណ៍ពិសេសកត់សំគាល់ពីទំនោរនៃតួអង្គនៅក្នុងការប្រកួតប្រជែងបោះឆ្នោត ក្នុងការកេងប្រវ័ញ្ចពីដើមកំណើតជាតិសាសន៍ ជាតិពន្ធុ សាសនា នយោបាយ ដើមកំណើតជាតិ ឬសង្គម ក្នុងចំណោមការបែងចែកដទៃទៀតដែលត្រូវបានហាមឃាត់យ៉ាងជាក់ស្តែងនៅក្នុងមាត្រា២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីផាត់ចេញដៃគូបដិបក្ស។ លោកសង្កត់ធ្ងន់ថា សិទ្ធិទាំងនេះ ត្រូវបានធានាការពារសំរាប់អ្នកទាំងអស់គ្នា ដោយឈរលើមូលដ្ឋានស្មើភាពគ្នា(A/HRC/20/27 កថាខ័ណ្ឌ១៣) ហើយថាដូច្នេះ រដ្ឋនានាត្រូវមានកាតព្វកិច្ចផ្តល់ការការពារដ៏មានប្រសិទ្ធភាពប្រឆាំងនឹងការរើសអើង។ នៅក្នុងបរិបទនៃការបោះឆ្នោត ត្រូវដាក់ចេញនូវវិធានការបណ្តោះអាសន្នណាមួយ ដើម្បីពង្រឹងលទ្ធភាពរបស់ក្រុមងាយរងគ្រោះឬក្រុមដែលប្រឈមនឹងហានិភ័យបំផុតពីការប្រើប្រាស់សិទ្ធិរបស់ពួកគេដូចជា ស្ត្រី ជនរងគ្រោះពីការរើសអើងដោយសារគោលដៅផ្លូវភេទ និងអត្តសញ្ញាណកម្មយេនឌ័ររបស់ពួកគេ យុវជន ជនទាំងឡាយនៃជនភាគតិច ជនជាតិដើមភាគតិច ជនគ្មានសញ្ជាតិ រួមទាំងជនគ្មានរដ្ឋ ជនភៀសខ្លួន ឬជនអន្តោរប្រវេសន្ត និងសមាជិកក្រុមសាសនា ព្រមទាំងសកម្មជនតស៊ូមតិពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងត្រូវប្រើជាយន្តការធ្វើឱ្យទីលានប្រកួតប្រជែងស្មើភាពគ្នា មិនបង្កើតជាការរើសអើង។

## III. សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី

១៦. សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងសមាគម ទាំងរៀបចំ ទាំងចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី ទាំងខាងក្នុង ទាំងខាងក្រៅ មានភស្តុតាងជាយូរមកហើយថា ជាធាតុផ្សំមួយយ៉ាងសំខាន់នៅក្នុងបរិបទនៃការបោះឆ្នោត។ សិទ្ធិនេះផ្តល់លទ្ធភាពឱ្យបេក្ខជន ចូលរួមក្នុងការបោះឆ្នោតបែបនេះ កៀងគរអ្នកគាំទ្ររបស់ខ្លួន និងផ្តល់ខ្លឹមសារនិងការឱ្យគេមើលឃើញពីសារនយោបាយរបស់ខ្លួន។ ការបោះឆ្នោត គឺជាឱកាសតែមួយគត់សំរាប់បុរស ស្ត្រី បុរស និងយុវជន មកពីគ្រប់ផ្នែកទាំងអស់នៃសង្គម ដើម្បីសំដែងទស្សនៈ និងបំណងប្រាថ្នារបស់ពួកគេ ទោះជាសំរាប់រក្សាស្ថានភាពដើម ឬការផ្លាស់ប្តូរក៏ដោយ គឺចង់និយាយថា ដើម្បីបញ្ចេញសម្លេងគាំទ្រ ឬសម្លេងជំទាស់រដ្ឋាភិបាល និងគណៈបក្សកាន់អំណាច។ សម្លេងជំទាស់នេះ គឺជាផ្នែកធម្មានុរូបមួយនៃការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីជាពិសេស ក្នុងបរិបទនៃការបោះឆ្នោត ដោយសារតែនោះគឺជាឱកាសតែមួយគត់សំរាប់ការសំដែងទស្សនៈពហុនិយមតាមរយៈមធ្យោបាយសន្តិវិធី។

១៧. ក្នុងករណីនេះដូចបានលើកឡើងក្នុងកំឡុងពេលកិច្ចពិភាក្សាក្រុមប្រឹក្សាសិទ្ធិមនុស្សស្ដីពីការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស នៅក្នុងបរិបទនៃការតវ៉ាដោយសន្តិវិធី អ្នករាយការណ៍ពិសេសយល់ឃើញថា ការចូលរួមក្នុងការតវ៉ាដោយសន្តិវិធី គឺជាជម្រើសផ្សេងក្រៅពីអំពើហិង្សា និងការប្រើកំលាំងអាវុធ ដោយសារតែវាជាមធ្យោបាយមួយនៃការសំដែងមតិ និងការផ្លាស់ប្តូរដែលគួរគាំទ្រ។ ដូច្នេះ សិទ្ធិនេះត្រូវទទួលបានការការពារ គឺត្រូវបានការពារយ៉ាងរឹងមាំ(សូមមើលA/HRC/19/40 កថាខ័ណ្ឌទី១៣)។ ក្រុមប្រឹក្សាសិទ្ធិមនុស្សសូមថែករំលែកនូវវិធីសាស្រ្តនេះ និងគូសបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ២២/១០ ថាការតវ៉ាដោយសន្តិវិធីមិនគួរត្រូវយល់ថាជាការគំរាមកំហែងនោះទេ ហេតុដូច្នេះ ក្រុមប្រឹក្សាបានលើកទឹកចិត្តឱ្យរដ្ឋទាំងអស់ ចូលរួមក្នុងកិច្ចសន្ទនាប្រកបដោយអត្ថន័យ បរិយាប័ន្ន និងបើកចំហនៅពេលដោះស្រាយជាមួយការតវ៉ាដោយសន្តិវិធី និងមូលហេតុនៃការតវ៉ានោះ។ ក្រុមប្រឹក្សាសង្កត់ធ្ងន់ទៀតថាមនុស្សគ្រប់រូប អាចសំដែងនូវទុក្ខសោក និងបំណងប្រាថ្នារបស់ខ្លួន តាមលក្ខណៈសន្តិវិធីមួយ រួមទាំង តាមរយៈការតវ៉ាជាសាធារណៈដោយគ្មានការភ័យខ្លាចពីការសងសឹក ឬពីការបំភិតបំភ័យ ការយាយី ការបង្ករបួសស្នាម ការបៀតបៀនផ្លូវភេទ ការវាយដំ ការចាប់ឬឃុំខ្លួនតាមទំនើងចិត្ត ទារុណកម្ម សំលាប់ ឬដាក់ឱ្យស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ។ បញ្ហានេះកាន់តែប្រាកដទៅទៀតនៅក្នុងបរិបទនៃការបោះឆ្នោត នៅពេលដែលភាពតានតឹងឈានដល់កំរិតកំពូល ដោយសារប្រយោជន៍ដ៏ច្រើនខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម ត្រូវប្រឈមនឹងហានិភ័យ។

១៨. ទោះជាយ៉ាងណាក៏ដោយ ការបោះឆ្នោតត្រូវបានធ្វើឱ្យអាស្រូវដោយការរំលោភ និងការបំពានសិទ្ធិមនុស្ស នៅតាមប្រទេសជាច្រើន។ តួយ៉ាង ក្នុងខែកញ្ញា ឆ្នាំ២០០៩ មានបាតុករជាង៥០.០០០នាក់ បានប្រមូលផ្តុំគ្នានៅក្នុងពហុកីឡដ្ឋានមួយក្នុងប្រទេសហ្គីណេ ធ្វើការតវ៉ាប្រឆាំងនឹងបេក្ខជនដែលអាចជាប់ឆ្នោត គឺលោកអនុសេនីយ៍មូសា ដាឌីស កាម៉ារ៉ា សំរាប់ការបោះឆ្នោតប្រធានាធិបតីក្នុងខែមករា ឆ្នាំ២០១០។ កងកំលាំងសន្តិសុខ បានបើកការវាយប្រហារ និងបានប្រើចំពុះទុង និងកាំបិត ដើម្បីបំបែកហ្វូងបាតុករ។ ជាលទ្ធផល ជាង១៥០នាក់ត្រូវបានសម្លាប់ និងជាង១០០០នាក់ត្រូវរងរបួស ជាច្រើននាក់ត្រូវចាប់ខ្លួននៅនឹងកន្លែង នៅតាមផ្ទះរបស់ពួកគេ ឬនៅក្នុងមន្ទីរពេទ្យ។ ក្នុងខែមិថុនាឆ្នាំ២០០៩ នៅសាធារណៈរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ បន្ទាប់ពីការប្រកាសពីជោគជ័យរបស់ប្រធានាធិបតីអាម៉ាឌីនចាត កងកំលាំងសន្តិសុខបានសំលាប់អ្នកតវ៉ាជាច្រើន នៅពេលដែលពួកគេបានដើរចេញនៅតាមដងផ្លូវដោយសន្តិវិធីជំទាស់នឹងលទ្ធផលនៃការបោះឆ្នោត។ កងកំលាំងសន្តិសុខបានបើកការវាយប្រហារនៅក្នុងកំឡុងពេលបាតុកម្មនិងបានប្រើដំបងនិងបាញ់ឧស្ម័នម្រេចដើម្បីបំបែកហ្វូងបាតុករ។បាតុករ

ជាច្រើនរយនាក់ត្រូវបានចាប់ខ្លួនបន្ទាប់ពីការបោះឆ្នោតប្រធានាធិបតីឆ្នាំ២០០៩។ នៅសហព័ន្ធរុស្ស៊ីការតវ៉ាដោយសន្តិវិធីប្រឆាំងនឹងការបោះឆ្នោតដែលត្រូវចោទថាមានការលួចបន្លំនៅក្នុងបរិបទនៃការបោះឆ្នោតសភា ដែលប្រព្រឹត្តិទៅនៅខែធ្នូ ឆ្នាំ២០១១ បានប្រឈមនឹងការប្រើប្រាស់កំលាំងដ៏ហួសហេតុ ហើយជាលទ្ធផល មនុស្សជាង១០០០នាក់ត្រូវបានឃុំខ្លួននៅតាមទីក្រុងផ្សេងៗ។ មានការកើតឡើងនូវអំពើផ្សេងៗនៃការឃាយី ការបំភិតបំភ័យ និងការឃុំខ្លួនតាមទំនើងចិត្តនូវសកម្មជន និងសមាជិកប្រឆាំងជាច្រើននាក់ នៅក្នុងបរិបទនៃការតវ៉ានឹងលទ្ធផលនៃការបោះឆ្នោតប្រធានាធិបតី កាលពីថ្ងៃទី៦ ឧសភា ២០១២។ នៅសាធារណៈរដ្ឋវេណេហ្ស៊ុយអេឡា ក្រោយពីការបោះឆ្នោតប្រធានាធិបតីខែមេសា ឆ្នាំ២០១៣ មានការធ្វើបាតុកម្មដោយសន្តិវិធីជាច្រើន នៅមុខការិយាល័យនានានៃគណៈកម្មការជាតិរៀបចំការបោះឆ្នោតនៅតាមរដ្ឋជាច្រើនត្រូវប្រឈមមុខនឹងការប្រើប្រាស់កំលាំងដ៏ឃោរឃៅដោយកងកំលាំងសន្តិសុខដោយរួមទាំងការចាប់ខ្លួនតាមទំនើងចិត្តផង។ នៅប្រទេសម៉ាឡេស៊ីកងកំលាំងសន្តិសុខបានប្រើកំលាំងដោយមិនរើសមុខ ដើម្បីបង្ក្រាបការតវ៉ាដោយសន្តិវិធី រៀបចំដោយសម្ព័ន្ធបោះឆ្នោតដោយសេរី និងត្រឹមត្រូវ (Bersih) ដែលតស៊ូមតិឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតនៅក្នុងប្រទេសនោះ។

**១៩.** ក្រៅពីការប្រើប្រាស់កម្លាំងហួសហេតុប្រឆាំងទៅនឹងអ្នកតវ៉ាដោយសន្តិវិធី នៅក្នុងករណីមួយចំនួន រដ្ឋបានកំណត់ជាទោសព្រហ្មទណ្ឌនូវការចូលរួម និងការរៀបចំការជួបប្រជុំដោយសន្តិវិធីក្នុងអំឡុងពេលនៃការបោះឆ្នោត ដើម្បីដាក់ទណ្ឌកម្ម ឬរារាំងអ្នកដែលមានឆន្ទៈ ឬដែលមានបំណងចង់ធ្វើដូច្នេះ។ នៅប្រទេសអេត្យូពី អ្នកតវ៉ាដោយសន្តិវិធី និងអ្នកការពារសិទ្ធិមនុស្សជាច្រើន ត្រូវបានចោទប្រកាន់ពីបទ "ឧក្រិដ្ឋនៃការបំពានបទបញ្ញាធម្មនុញ្ញ" និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិត ដោយសារតែបានចូលរួមនៅក្នុងបាតុកម្មប្រឆាំងនឹងការចោទប្រកាន់ពីការលួចបន្លំនៅក្នុងការបោះឆ្នោតសកល នៅខែឧសភា ឆ្នាំ២០០៥ ដែលក្នុងនោះ ក្រុមអ្នកតវ៉ាប្រមាណជាង១៩០នាក់ ត្រូវបានគេរាយការណ៍ថា ត្រូវបានសម្លាប់ដោយអាជ្ញាធរប្រតិបត្តិច្បាប់។ បន្ទាប់ពីចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍មួយដោយសារភាពថា សកម្មភាពរបស់ពួកគេផ្ទុយនឹងរដ្ឋធម្មនុញ្ញ ពួកគេបានទទួលការលើកលែងទោស និងត្រូវបានគេដោះលែង។ ក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោត នីតិបញ្ញត្តិនៅប្រទេសបារ៉ែន ក្នុងខែកញ្ញា ឆ្នាំ២០១១ អ្នកការពារសិទ្ធិមនុស្សជាច្រើន ព្រមទាំងសាច់ញាតិរបស់ពួកគេត្រូវបានចាប់ខ្លួន បណ្តេញចេញពីការងារ និងបានរងការគម្រាមកំហែង និងការឃាយីសម្រាប់បទល្មើសនយោបាយនានា រួមទាំង "ការចូលរួមក្នុងការប្រមូលផ្តុំដោយខុសច្បាប់"។ បន្ទាប់ពីការបោះឆ្នោតប្រធានាធិបតីនៅខែធ្នូ ឆ្នាំ២០១០ នៅប្រទេសបេឡារុស មនុស្សរាប់រយនាក់ដែលបានតវ៉ានឹងការបោះឆ្នោតពេលយប់ ត្រូវបានឃុំខ្លួន រួម

ទាំងសកម្មជនសង្គមស៊ីវិល អ្នកសារព័ត៌មាន និងថ្នាក់ដឹកនាំគណបក្សប្រឆាំង រួមទាំងបេក្ខជនប្រធានាធិបតីផងដែរ។ អ្នកតវ៉ាដោយសន្តិវិធីម្នាក់ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ និង៦ខែ ដោយឱ្យធ្វើការងារទាំងបង្ខំ ពីបទធ្វើឲ្យខូចសណ្តាប់ធ្នាប់ទ្រង់ទ្រាយធំ ចំពោះការចូលរួមរបស់គាត់ ក្នុងការតវ៉ាដោយសន្តិវិធី។ គាត់ត្រូវបានគេឃុំខ្លួនដំបូងសម្រាប់បទល្មើសរដ្ឋបាល ប៉ុន្តែក្រោយមកត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ទោះបីជាមន្ត្រីនគរបាលដែលមានដីកាចាប់ខ្លួនគាត់បានថ្លែងក្នុងតុលាការថាលោកពិតជាមិនបានឃើញគាត់ក្នុងអំឡុងពេលនៃការតវ៉ានេះក៏ដោយ។ ស្រដៀងគ្នានេះដែរនៅសហព័ន្ធរុស្ស៊ី ការចោទ ប្រកាន់ពីបទ"ធ្វើឲ្យខូចសណ្តាប់ធ្នាប់ទ្រង់ទ្រាយធំ" ត្រូវបានធ្វើឡើងប្រឆាំងនឹងអ្នកតវ៉ាដោយ សន្តិវិធីក្នុងអំឡុងពេលបោះឆ្នោត។ បាតុករជាច្រើននាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទ "បំភិតបំភ័យជាសាធារណៈ" និង "ការញុះញង់ជាសាធារណៈ"។ បាតុករដោយសន្តិវិធីនៅប្រទេសអាហ្សែបៃហ្សង់ ត្រូវបានកំណត់ជាគោលដៅកាន់តែកើនឡើង នៅក្នុងបរិបទនៃការបោះឆ្នោតនាពេលខាងមុខ ក្នុងខែតុលា ឆ្នាំ២០១៣ ដោយពួកគេមួយចំនួន ត្រូវបានចាប់ខ្លួន និង/ឬពិន័យជាប្រាក់។ នៅប្រទេសនេប៉ាល់ ក្នុងខែមករា ឆ្នាំ២០០៦ អ្នកការពារសិទ្ធិមនុស្សចំនួន៤នាក់ ត្រូវបានចាប់ខ្លួន ដោយសារតែការចូលរួមរបស់ពួកគេនៅក្នុងការរៀបចំបាតុកម្មដោយសន្តិវិធីដែលមានទ្រង់ទ្រាយធំ ដោយបានអំពាវនាវឱ្យធ្វើពហិការចំពោះការបោះឆ្នោតរាជធានីដែលគ្រោងធ្វើនៅខែបន្ទាប់។

២០. អ្នករាយការណ៍ពិសេស ព្រមានប្រឆាំងនឹងការឃុំខ្លួនអ្នកតវ៉ាដោយសន្តិវិធី ដើម្បីបង្ការការចូលរួមរបស់ពួកគេ ក្នុងការជួបប្រជុំដែលរិះគន់រដ្ឋាភិបាល ឬគណៈបក្សកាន់អំណាច។ លោកក៏មានការព្រួយបារម្ភដូចគ្នានេះដែរអំពីបទបញ្ញាវិតត្បិតហាមឃាត់បាតុករ និងក្រុមអ្នកការពារសិទ្ធិមនុស្សដែលឃ្លាំមើលការជួបប្រជុំពីការស្ថិតនៅចេញ-ចូល ឬឆ្លងកាត់ទីក្រុងមួយដូចបានកើតឡើងជាឧទាហរណ៍នៅក្នុងប្រទេសម៉ាឡេស៊ី កាលពីខែកក្កដា ឆ្នាំ២០១១។

២១. ជាមូលដ្ឋាន អ្នករាយការណ៍ពិសេសជឿជាក់ថា ការជួបប្រជុំដោយសន្តិវិធីទាំងអស់ធ្វើឡើងក្នុងអំឡុងដំណើរការបោះឆ្នោត បើទោះបីជាគាំទ្រ ឬមិនគាំទ្រគណៈបក្សកាន់អំណាច ឬរដ្ឋាភិបាលកំពុងកាន់តំណែងក៏ដោយ គួរតែមានសិទ្ធិទទួលបានការប្រព្រឹត្តលើដោយស្មើភាពគ្នា។ ការជួបប្រជុំបែបនេះគួរតែទទួលបានការការពារនិងការសម្របសម្រួលពីរដ្ឋដោយស្មើភាពគ្នា នៅក្នុងការបំពេញកាតព្វកិច្ចវិជ្ជមានរបស់ខ្លួនក្នុងរឿងនេះ ដោយមិនគិតពីប្រភេទ ឬក្រុមបាតុករនោះជានរណានោះឡើយ។ នៅក្នុងបញ្ហានេះ អ្នករាយការណ៍ពិសេសព្រមានប្រឆាំងនឹងភាពងាយរងគ្រោះកាន់តែកើនឡើង នៃក្រុមជនងាយរងគ្រោះដែលបាននិយាយខាងលើនេះ ឬក្រុមដែលងាយរងហានិភ័យបំផុតពីការវាយប្រហារនានា ការធ្វើអធិប្បាយដែលមានការប្រមាថ ការមាក់ងាយ និងការរិតត្បិតមិនសមហេតុផល ដើម្បីបំបើឱ្យរបៀបវារៈ

នយោបាយ ដែលជាញឹកញាប់មកពីគណៈបក្សនយោបាយផ្សេងៗគ្នា។ ពួកគេមួយចំនួនអាចប្រឈមផងដែរនឹងការដកហូតលិខិតឆ្លងដែន និងប័ណ្ណការងារសម្រាប់ការចូលរួមក្នុងការតវ៉ាដោយសាមគ្គីភាព។ ជាផលវិបាក ការជួបប្រជុំដោយសន្តិវិធីដែលបានរៀបចំដោយក្រុមទាំងនេះ ដែលប្រហែលជាចង់យកឱកាសនៃការបោះឆ្នោតដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះការលំបាករបស់ខ្លួន ត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ អ្នករាយការណ៍ពិសេស មានភាពរន្ធត់ដោយឧប្បត្តិហេតុខាងលើនេះ នៅប្រទេសហ្គីណេ ក្នុងខែកញ្ញា ឆ្នាំ២០០៩ដែលស្ត្រីជាច្រើនរូបបានចូលរួមនៅក្នុងបាតុកម្មនេះឬដែលមានវត្តមាននៅក្នុងតំបន់នេះ ត្រូវបានគេសម្រាតខោអាវនិងបំពានខាងផ្លូវភេទ រួមទាំងការចាប់រំលោភបូក ទាំងនៅឯកីឡាដ្ឋាន និងនៅមន្ទីរឃុំឃាំង។ នៅប្រទេសហ្ស៊ីមបាវេ ក្រុមបាតុករដោយសន្តិវិធីដែលធ្វើការតស៊ូមតិគាំទ្រសិទ្ធិស្ត្រី ត្រូវបានគេធ្វើបាបនៅក្នុងបរិបទនៃការបោះឆ្នោត។ នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ សិស្សប្រាំនាក់ក្នុងចំណោមពួកគេ ត្រូវបានសម្លាប់ដោយកងកម្លាំងសន្តិសុខនៅក្នុងខែមិថុនា ឆ្នាំ២០០៩។

**២២**. ច្បាប់ទាំងឡាយដែលអនុម័តដោយមហាសន្និបាត ដែលនាំមកនូវការទទួលបានសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ គួរយកមកអនុវត្តទៅតាមព្រឹត្តិការណ៍ដែលទាក់ទងទៅនឹងដំណើរការនៃការបោះឆ្នោត។ ជាពិសេសច្បាប់ទាំងនេះគួរតែអនុញ្ញាត និងជួយសម្រួលដល់ការជួបប្រជុំដោយឯកឯង ដោយចងចាំថាតម្រូវការឱ្យមានការអត់ឱនកាន់តែច្រើន នៅក្នុងកំឡុងពេលនៃការបោះឆ្នោត គឺពេលនេះហើយដែលទស្សនៈ និងមតិផ្សេងៗគ្នាជាច្រើនត្រូវបានសម្តែងឡើង។

**២៣**. ផ្នែកកណ្តាលនៃកាតព្វកិច្ចជាវិជ្ជមានរបស់រដ្ឋ ដើម្បីការពារអ្នកដែលប្រើសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីគឺធានាពីការការពារប្រឆាំងនឹងភ្នាក់ងារបង្កហេតុនិងបដិបាតុករដែលគោលបំណងរបស់ពួកគេ គឺដើម្បីរំខាន ឬបំបែកការជួបប្រជុំបែបនេះ។ បុគ្គលបែបនេះរួមមានអ្នកដែលជាកម្មសិទ្ធិរបស់បរិធានរដ្ឋឬធ្វើការនៅក្នុងនាមរដ្ឋ។អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភអំពីការប្រើប្រាស់ភ្នាក់ងារបង្កហេតុរបស់រដ្ឋ ដើម្បីរំខានដល់ការជួបប្រជុំដូចករណីដែលត្រូវបានរាយការណ៍នៅក្នុងប្រទេសសេណេហ្គាល់ ក្នុងខែមករា ឆ្នាំ២០១២ មុនពេលនៃការបោះឆ្នោតប្រធានាធិបតីជុំទីមួយ។ ស្រដៀងគ្នានេះដែរ គួរតែមានកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លា ដើម្បីអនុញ្ញាត ការពារ និងជួយសម្រួលដល់ការជួបប្រជុំដោយសន្តិវិធីដែលបណ្តាក់គ្នា និងបដិបាតុកម្មដោយសន្តិវិធី នៅពេលណាដែលអាចធ្វើបាន។ សរុបមករាល់ទម្រង់នៃការជួបប្រជុំដោយសន្តិវិធី គួរតែទទួលបានការការពារ និងការសម្របសម្រួលកាន់តែច្រើនពីអាជ្ញាធរ។

២៤. ក្នុងន័យនេះអ្នករាយការណ៍ពិសេសរំលឹកថាសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី មិនតម្រូវឱ្យមានការចេញលិខិតអនុញ្ញាតណាមួយឱ្យរៀបចំការជួបប្រជុំនោះទេ។ បើចាំបាច់ អាចតម្រូវឱ្យមានការជូនដំណឹងជាមុន សម្រាប់ការជួបប្រជុំទ្រង់ទ្រាយធំ ឬសម្រាប់ការជួបប្រជុំដែលកម្រិតនៃការរំខានត្រូវបានប្រមើលឃើញជាមុន។ ការជួបប្រជុំដោយសន្តិវិធីដោយឯកឯង ដែលជាធម្មតាកើតឡើងនៅក្នុងប្រតិកម្មតបទៅនឹងព្រឹត្តិការណ៍ជាក់លាក់មួយ-ដូចជាការប្រកាសលទ្ធផល-និងដែលតាមអត្ថន័យមិនអាចជាកម្មវត្ថុនៃការជូនដំណឹងជាមុន គួរតែត្រូវបានអត់ឱនឱ្យបានច្រើននៅក្នុងបរិបទនៃការបោះឆ្នោត។ លើសពីនេះទៅទៀត អ្នករាយការណ៍ពិសេសចាត់ទុកច្បាប់ទាំងឡាយដែលបង្កើតនីតិវិធីផ្តល់ការអនុញ្ញាត គឺមានតែបង្កើតបញ្ហា នៅក្នុងបរិបទនៃការបោះឆ្នោត ដោយសារតែការអនុញ្ញាត អាចត្រូវបានបដិសេធតាមទំនើងចិត្ត ជាពិសេស នៅពេលដែលក្រុមបាតុករ មានបំណងរិះគន់គោលនយោបាយរបស់រដ្ឋាភិបាល។ នៅប្រទេសស្វ៊ូដង់ បាតុកម្មដោយសន្តិវិធីមួយដែលរៀបចំឡើងដោយបេក្ខជនអភិបាលខេត្តឯករាជ្យមួយសម្រាប់ការបោះឆ្នោតខែមេសា ឆ្នាំ២០១០ ត្រូវបានទប់ស្កាត់ដោយកងកម្លាំងប៉ូលីស ដោយយកហេតុពីការខកខានរបស់អ្នករៀបចំដើម្បីស្វែងរកការអនុញ្ញាត។ ក្រុមអ្នកតវ៉ាមួយចំនួនត្រូវបានចាប់ខ្លួន និង/ឬរងរបួសដោយកងកម្លាំងសន្តិសុខ។

២៥. ផ្ទុយទៅវិញ ការបោះឆ្នោតមិនគួរត្រូវបានឃើញថាជាលេសមួយសម្រាប់រដ្ឋក្នុងការរឹតត្បិតមិនសមហេតុផល ទៅលើសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនោះឡើយ។ ដូចបានរៀបរាប់ខាងលើ បម្រាមគ្រប់ទិដ្ឋភាព ដែលមានភាពរើសអើង និងអសមាមាត្រជាមូលដ្ឋាន គួរតែត្រូវបានហាមឃាត់ ហើយការរឹតត្បិតលើការជួបប្រជុំដោយសន្តិវិធីទាក់ទងទៅនឹង "ពេលវេលា ទីកន្លែង និងលក្ខណៈ" របស់វា គួរតែត្រូវបានកម្រិតទៅតាមវិសាលភាពដែលថាការរឹតត្បិតបែបនេះ បំពេញតាមលក្ខខណ្ឌតឹងរឹងនៃភាពចាំបាច់ និងសមាមាត្រដូចមានបញ្ជាក់ខាងលើ (សូមមើល A/HRC/23/39, កថាខ័ណ្ឌទី៥៩)។ ជាការពិត ដោយសារសារៈសំខាន់នៃសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម នៅក្នុងបរិបទនៃការបោះឆ្នោត ព្រំដែនសម្រាប់ដាក់ការរឹតត្បិតបែបនេះគួរតែធ្វើដោយការគិតពិចារណាខ្ពស់ជាងធម្មតា៖ លក្ខណៈវិនិច្ឆ័យនៃ "ភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ" និង "សមាមាត្រ" គួរតែមានភាពលំបាកបន្ថែមទៀតដើម្បីបំពេញតាមក្នុងអំឡុងពេលបោះឆ្នោត។ ក្នុងន័យនេះ អ្នករាយការណ៍ពិសេសមានសេចក្តីស្រងាកចិត្តដែលថា បម្រាមគ្រប់ទិដ្ឋភាព ត្រូវបានយកមកប្រើប្រាស់ក្នុងអំឡុងពេលបោះឆ្នោត ដើម្បីបិតមាត់សំលេងជំទាស់ទាំងឡាយ។ បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោតប្រធានាធិបតីនៅប្រទេសកេនយ៉ា ក្នុងខែមីនា ឆ្នាំ២០១៣ មានសេចក្តីរាយការណ៍ថាប្រធានប៉ូលីសបានហាមឃាត់គ្រប់ការប្រមូលផ្តុំជាសាធារណៈរួមទាំង "ការចងក្រងក្រុមខុសច្បាប់" នៅជុំវិញតុលាការកំពូល កិច្ចប្រជុំបន់ស្រន់ កិច្ចប្រជុំ និងការ

ប្រមូលផ្តុំនយោបាយ រហូតទាល់តែញត្តិជំទាស់នឹងលទ្ធផលនៃការបោះឆ្នោតប្រធានាធិបតីត្រូវបានជំនុំជំរះ និងសម្រេចសេចក្តី។ តាមសេចក្តីរាយការណ៍ សេចក្តីសម្រេចនេះ ត្រូវបានដាក់ចេញដោយផ្អែកលើអង្គហេតុដែលថាការធ្វើបាតុកម្មអាចជាឆ្នួនផ្ទុះនៃការបង្កហិង្សា និងប្រទូស្តរាយ។ នៅពេលដែលធ្វើយុត្តិកម្មពី "ពេលវេលា ទីកន្លែង និងលក្ខណៈ" ការរិតត្បិតដែលអនុលោមទៅតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ គួរត្រូវយកមកអនុវត្តដោយស្មើភាពគ្នា ហើយជាថ្មីម្តងទៀត មិនថាការជួបប្រជុំដោយសន្តិវិធីនេះ ធ្វើឡើងដើម្បីគាំទ្រ ឬប្រឆាំងនឹងរដ្ឋាភិបាល និងគណៈបក្សកាន់អំណាចនោះទេ។

**២៦.** អ្នករាយការណ៍ពិសេស ព្រមានបន្ថែមទៀតប្រឆាំងនឹងការដាក់រដ្ឋស្ថិតក្នុងភាពអាសន្នក្នុងអំឡុងពេលបោះឆ្នោត ដើម្បីព្យួរជាបណ្តោះអាសន្ននូវសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី។ បើទោះជាវាគួរកើតឡើងក៏ដោយ លោករំឭកថា យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនិងសមាគមមិនគួរត្រូវបានព្យួរនោះទេក្នុងអំឡុងពេលរដ្ឋស្ថិតក្នុងភាពអាសន្ន ដោយសារតែលទ្ធភាពនៃការរិតត្បិតសិទ្ធិជាក់លាក់មួយចំនួននៃកតិកាសញ្ញា ក្រោមលក្ខខណ្ឌនៃសេរីភាពក្នុងការជួបប្រជុំជាឧទាហរណ៍ ជាទូទៅមានលក្ខណៈគ្រប់គ្រាន់ហើយនៅក្នុងស្ថានភាពបែបនេះ ហើយគ្មានការព្យួរសិទ្ធិទាំងនោះនឹងត្រូវធ្វើយុត្តិកម្មដោយសារតែតម្រូវការជាប្រញាប់នៃស្ថានភាពនេះនោះទេ។[១០]

**២៧.** អ្នករាយការណ៍ពិសេសរំឭកថា អ្នករៀបចំការតវ៉ាដោយសន្តិវិធីមិនគួររ៉ាប់រងការទទួលខុសត្រូវចំពោះឥរិយាបថខុសច្បាប់របស់អ្នកដទៃនោះទេ រួមទាំងក្នុងពេលវេលានៃការបោះឆ្នោត។ នៅប្រទេសម៉ាឡេស៊ី ក្នុងខែឧសភា ឆ្នាំ២០១២ រដ្ឋាភិបាលសហព័ន្ធបានប្រកាសថាខ្លួននឹងប្តឹងអ្នករៀបចំក្រុម Bersih3.0 ចំពោះការប្រមូលផ្តុំនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១២ ដែលបានអំពាវនាវឱ្យមានការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលមានការចោទប្រកាន់ថាត្រូវបានបំផ្លាញក្នុងអំឡុងពេលនៃការជួបប្រជុំនោះ។

**២៨.** វាក៏មានសារៈសំខាន់ផងដែរ ក្នុងការអនុញ្ញាតឱ្យមានសិទ្ធិទទួលបាន និងប្រើប្រាស់ដោយមិនមានការរារាំងនូវអ៊ិនធឺណិត ជាពិសេស ប្រព័ន្ធផ្សព្វផ្សាយសង្គម និងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងផ្សេងទៀត ដែលជាឧបករណ៍ដ៏សំខាន់ ជាពិសេសនៅក្នុងពេលវេលានៃការបោះឆ្នោត ដែលតាមរយៈនោះ សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី អាចត្រូវបានអនុវត្ត ក៏ប៉ុន្តែក៏ត្រូវមានការឃ្លាំមើល និងរាយការណ៍ផងដែរ ពាក់ព័ន្ធនឹងការរំលោភ និងការបំពានសិទ្ធិមនុស្ស។ នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ នៅក្នុងបរិបទនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ២០០៩ សិទ្ធិទទួលបាននូវប្រព័ន្ធផ្សព្វផ្សាយសង្គម ត្រូវបានបិទជាបណ្តោះ

[១០] សេចក្តីពន្យល់ទូទៅលេខ២៩(ឆ្នាំ២០០១) ស្តីពីការព្យួរសិទ្ធិនៃកតិកាសញ្ញាក្នុងគ្រាអាសន្ន កថាខណ្ឌទី៥។

អាសន្ននៅទូទាំងប្រទេស ដោយសារតែមានbloggersជាច្រើនបានរាយការណ៍អំពីការរំលោភបំពានប្រឆាំងនឹងអ្នកតវ៉ាដោយសន្តិវិធី ហើយប្រព័ន្ធផ្សព្វផ្សាយបរទេស ត្រូវបានបដិសេធពីសិទ្ធិទទួលបានការប្រើប្រាស់នេះ។ នៅប្រទេសនេប៉ាល់ ពាក់ព័ន្ធនឹងការធ្វើបាតុកម្មដូចបានរៀបរាប់ខាងលើ ប្រព័ន្ធទូរស័ព្ទខ្សែ និងទូរស័ព្ទដៃ ត្រូវបានកាត់ផ្តាច់នៅទីក្រុងកាត់តាម៉ាន់ឌូ និងទីក្រុងសំខាន់ៗដទៃទៀតដោយអាជ្ញាធរនេប៉ាល់។

២៩. ជាទីបញ្ចប់អ្នករាយការណ៍ពិសេសសង្កត់ធ្ងន់ម្តងទៀតអំពីតួនាទីយ៉ាងសំខាន់របស់អ្នកការពារសិទ្ធិមនុស្ស រួមទាំងអ្នកសារព័ត៌មានដែលឃ្លាំមើលការជួបប្រជុំ ហើយត្រូវបានក្លាយជាគោលដៅនៅក្នុងបរិបទនៃការបោះឆ្នោត។ នៅប្រទេសបេឡារុស ក្នុងខែធ្នូ ឆ្នាំ២០១០ ប្រធានគណៈកម្មាធិការហែលស៊ីនគីបេឡារុស ក្នុងចំណោមសកម្មជនដទៃទៀត ត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយកងកម្លាំងសន្តិសុខ ខណៈពេលកំពុងសង្កេតការណ៍បាតុកម្មមួយដែលរៀបចំដោយបេក្ខជនប្រឆាំងមួយរូប ដែលត្រូវបានប្រារព្វធ្វើនៅមុខទីស្នាក់ការកណ្តាលរបស់រដ្ឋាភិបាល។ គាត់ត្រូវបាននាំខ្លួនទៅកាន់កន្លែងឃុំខ្លួនបណ្តោះអាសន្ន មុនពេលត្រូវបានឃុំខ្លួននៅប៉ូលីស។នៅប្រទេសម៉ាឡេស៊ីបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយដែលកំពុងធ្វើការអំពីការតវ៉ាមួយដែលរៀបចំដោយក្រុមBersih ត្រូវបានក្លាយគោលដៅរបស់កងកម្លាំងសន្តិសុខ ខណៈពេលដែលពួកគេកំពុងថតជាឯកសារពីភាពព្រៃផ្សៃរបស់ប៉ូលីស ទោះបីជាពួកគេមានបង្ហាញអត្តសញ្ញាណយ៉ាងច្បាស់លាស់ថាជាបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយនោះក៏ដោយ។

## IV សេរីភាពខាងសមាគម

### *ក. គណៈបក្សនយោបាយ*

៣០. ជនគ្រប់រូបមានសិទ្ធិបង្កើត ឬចូលរួមក្នុងគណៈបក្សនយោបាយមួយ ហើយផ្ទុយមកវិញគ្មានជនណាម្នាក់ត្រូវបានបង្ខំឲ្យធ្វើជាសមាជិកគណៈបក្សនយោបាយណាមួយនោះទេ។នៅក្នុងសេចក្តីពន្យល់ទូទៅរបស់ខ្លួនលេខ២៥ (កថាខណ្ឌទី២៦) គណៈកម្មាធិការសិទ្ធិមនុស្សបានថ្លែងថា គណៈបក្សនយោបាយ និងសមាជិកនៅក្នុងគណៈបក្ស ដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំកិច្ចការសាធារណៈ និងដំណើរការបោះឆ្នោត។ តាមពិតទៅ គណៈបក្សនយោបាយគឺជាមធ្យោបាយដំបូងដែលតាមរយៈនេះ មនុស្សអាចចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈបាន។ អ្នករាយការណ៍ពិសេស ទទួលស្គាល់គណៈបក្សនយោបាយថាជាសំណុំរងមួយនៃសមាគម រាប់ទាំងសិទ្ធិសេរីភាពខាងសមាគម ដូចមានចែងក្នុងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ដូច្នេះ គោលការណ៍ និងបទដ្ឋានអប្បបរិមា ដែលបានអធិប្បាយដោយអ្នករាយការណ៍ពិសេស នៅក្នុងរបាយការណ៍តាមវិស័យរបស់លោកស្តីពីការអនុវត្តន៍ល្អប្រពៃ (A/HRC/20/27) អនុវត្តជាទូទៅចំពោះបទប្បញ្ញត្តិនៃ

គណៈបក្សនយោបាយ។ ទោះជាយ៉ាងនេះក៏ដោយ គណៈបក្សនយោបាយ ជាអង្គការដែលបង្កើតឡើងដើម្បីអនុវត្តគោលបំណងដោយឡែក នោះគឺការបង្ហាញបេក្ខជនសម្រាប់ការបោះឆ្នោតដើម្បីឲ្យធ្វើជាតំណាងនៅក្នុងស្ថាប័ននយោបាយ និងដើម្បីអនុវត្តអំណាចនយោបាយនៅកម្រិតណាមួយ នៅកម្រិតជាតិ ឬនៅកម្រិតមូលដ្ឋាន[១១] ហើយហេតុដូច្នេះអាចស្ថិតក្រោមលក្ខខណ្ឌតម្រូវជាក់លាក់ ដែលមិនចាំបាច់សម្រាប់អង្គការសង្គមស៊ីវិលដទៃទៀត។ យោងតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប នេះជាប្រភេទតួនាទីដែលពួកគេត្រូវធ្វើ គឺថាគណៈបក្សនយោបាយដែលជាស្ថាប័នតែមួយគត់ដែលអាចចូលមកកាន់អំណាចក៏មានសមត្ថភាពជះឥទ្ធិពលទៅលើរបបទាំងមូល នៅក្នុងប្រទេសរបស់ពួកគេផងដែរ។ តាមរយៈសំណើសម្រាប់គំរូបែបសង្គមជារួមមួយ ដែលពួកគេបានដាក់នៅចំពោះមុខអ្នកបោះឆ្នោត និងតាមរយៈសមត្ថភាពរបស់ពួកគេដើម្បីអនុវត្តសំណើទាំងនោះនៅពេលដែលពួកគេឡើងកាន់អំណាច គណៈបក្សនយោបាយខុសពីអង្គការដទៃទៀតដែលធ្វើអន្តរាគមន៍នៅក្នុងឆាកនយោបាយ។[១២]

**៣១.** អ្នករាយការណ៍ពិសេសយល់ស្របនឹងគណៈកម្មាធិការសិទ្ធិមនុស្ស នៅក្នុងកថាខណ្ឌ ១៩ នៃសេចក្តីពន្យល់ទូទៅលេខ២៥ ដែលថា សេរីភាពនៃការបញ្ចេញមតិ ការជួបប្រជុំ និងសមាគម គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តដ៏មានប្រសិទ្ធិភាពនូវសិទ្ធិបោះឆ្នោត និងត្រូវទទួលបានការការពារយ៉ាងពេញលេញ ហើយរដ្ឋគួរធានាឱ្យបានថា នៅក្នុងការគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន គណៈបក្សនយោបាយគោរពបទប្បញ្ញត្តិនៃមាត្រា២៥ ដែលកំពុងតែនៅអនុវត្ត ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដូចមានចែងនៅក្នុងបទប្បញ្ញត្តិនេះ។ ដូចដែលអ្នករាយការណ៍ពិសេសបានកត់សម្គាល់កាលពីលើកមុន ចំនួនអប្បបរមានៃបុគ្គលអាចជាលក្ខខណ្ឌតម្រូវ ដើម្បីបង្កើតគណៈបក្សនយោបាយមួយ ក៏ប៉ុន្តែចំនួននេះ មិនគួរត្រូវកំណត់នៅក្នុងកម្រិតមួយ ដែលមិនលើកទឹកចិត្តមនុស្សឱ្យចូលរួមក្នុងសមាគមនោះទេ(A/HRC/20/27 កថាខណ្ឌទី៥៤)។ លក្ខខណ្ឌតម្រូវផ្សេងទៀតអាចនៅជាធរមាន ដូចជាទាក់ទងនឹងតំណាងតាមភូមិសាស្រ្ត ឬជាតិពន្ធុជាដើម ក៏ប៉ុន្តែអ្នករាយការណ៍ពិសេសព្រមានប្រឆាំងនឹងប្រភេទនៃវិធានការណ៍នេះដែលនៅទីបំផុតគឺជាការរើសអើងដល់ការបង្កើតគណៈបក្សនយោបាយណាមួយ។ របបចុះបញ្ជីមិនមានភាពចាំបាច់ដល់ការបង្កើត ឬប្រតិបត្តិនៃគណៈបក្សនយោបាយនោះទេ ក៏ប៉ុន្តែបើសិនជាត្រូវដាក់ឱ្យអនុវត្ត វាមិនគួរជាកម្មវត្ថុនៃការអនុម័តជាមុនរបស់អាជ្ញាធរនោះទេ។

---

[១១] គណៈកម្មការអឺរ៉ុបសំរាប់លទ្ធិប្រជាធិបតេយ្យ តាមរយៈច្បាប់ គណៈកម្មការវ៉ឺនីស ក្រមសីលធម៌នៃការអនុវត្តជាប្រពៃ នៅក្នុងវិស័យគណៈបក្សនយោបាយ ២០០៩ CDL-AD (2009)021

[១២] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីរវាងគណៈបក្សសុខុមាលភាពនិងគណៈបក្សដទៃទៀត ប្រឆាំងនឹងប្រទេសទួគី សេចក្តីអនុវត្តលេខ៤១៣៤០/៩៨ លេខ៤១៣៤២/៩៨ លេខ៤១៣៤៣/៩៨ និងលេខ៤១៣៤៤/៩៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០០៣ កថាខ័ណ្ឌទី៨៧។

**៣២.** ជាការពិតណាស់ថា គណៈបក្សនយោបាយមានតួនាទីធ្វើសេចក្តីសម្រេចក្នុងការធានា របបពហុនិយម និងដំណើរការប្រព្រឹត្តទៅដ៏ត្រឹមត្រូវនៃលទ្ធិប្រជាធិបតេយ្យ សច្ចធារណ៍មួយ គាំទ្រដល់ការបង្កើតគណៈបក្សនយោបាយមានន័យថា សេចក្តីសម្រេចជាអវិជ្ជមានគួរត្រូវ បានធ្វើយុត្តិកម្មយ៉ាងតឹងរឹង ស្របតាមបទដ្ឋានដែលបង្កើតឡើងដោយមាត្រា២២ នៃកតិកា សញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ទាក់ទងទៅនឹងភាពសមាមាត្រ និងភាព ចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។ ដើម្បីគាំទ្រដល់សិទ្ធិសេរីភាពនៃការជួបប្រជុំដោយ សន្តិវិធី អ្នករាយការណ៍ពិសេសជឿជាក់ថា ការដាក់លក្ខខណ្ឌពីភាពសមាមាត្រ និងភាព ចាំបាច់គួរតែតឹងរឹងជាងនៅក្នុងពេលវេលានៃការបោះឆ្នោត។ នៅឆ្នាំ២០១១ ការព្រួយបារម្ភ ជាច្រើនត្រូវបានសម្តែងឡើង អំពីករណីរបស់ប្រជាពលរដ្ឋអារ៉ាប៊ីសាអ៊ូឌីតមួយចំនួន ដែល បានដាក់សំណើសុំឱ្យមានការទទួលស្គាល់ ពីអ្វីដែលអាចជាគណៈបក្សនយោបាយទីមួយ របស់អារ៉ាប៊ីសាអ៊ូឌីត ហើយដែលត្រូវបានឃាត់ខ្លួននាប៉ុន្មានថ្ងៃក្រោយមកនិងត្រូវបានស្នើឱ្យ ចុះហត្ថលេខាធានាថា ពួកគេនឹងបោះបង់ចោលសកម្មភាពរបស់ពួកគេជាមួយគណៈបក្ស នេះ។អ្នកដែលបានបដិសេធមិនព្រមធ្វើដូច្នេះត្រូវបានដាក់ក្នុងការឃុំឃាំង។អ្នករាយការណ៍ ពិសេស បានចាត់ទុកករណីនេះ ជាឧទាហរណ៍មួយនៃការរំលោភបំពានដោយចំហមួយនៃ សិទ្ធិសេរីភាពខាងសមាគម។ តាមគ្រប់មធ្យោបាយ គណៈបក្សនយោបាយ ដែលឯកសារ ពាក្យសុំរបស់ខ្លួនត្រូវបានបដិសេធ គួរតែត្រូវបានផ្តល់ឱកាសឱ្យស្វែងរកដំណោះស្រាយ នៅ ចំពោះមុខតុលាការមួយដែលឯករាជ្យនិងមិនលំអៀង(A/HRC/20/27កថាខណ្ឌទី៦០-៦១)។

**៣៣.** គណៈបក្សនយោបាយមានសិទ្ធិទទួលបានទីលានប្រកួតប្រជែងស្មើភាពគ្នាមួយ ដើម្បី ប្រកួតប្រជែងដោយយុត្តិធម៌ក្នុងការបោះឆ្នោត។ ទីលានប្រកួតប្រជែងស្មើភាពគ្នាមួយ មិន មែនមានន័យថាគណៈបក្សនយោបាយទាំងអស់ត្រូវទទួលបាននូវការប្រព្រឹត្តដូចគ្នានៅគ្រប់ ករណីនោះទេ ជាជាងគណៈបក្សទាំងនេះគួរទទួលបានការប្រព្រឹត្តស្មើគ្នា ដោយផ្អែកលើ លក្ខណៈវិនិច្ឆ័យជាសត្យានុម័ត និងសមហេតុផល។ គណៈបក្សទាំងអស់ ដែលអនុវត្តតាម បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិមានសិទ្ធិទទួលបាននូវកាលានុវត្តភាពស្មើភាពគ្នា។ ដូច្នេះត្រឹម កំរិតអប្បបរមាគ្មានគណៈបក្សនយោបាយណាមួយត្រូវបានរើសអើងប្រឆាំងដោយរដ្ឋដោយ សារតែគុណសម្បត្តិ និងគុណវិបត្តិដែលមិនត្រឹមត្រូវនោះឡើយ។ នៅក្នុងរបាយការណ៍នេះ អ្នករាយការណ៍ពិសេស សង្កត់ធ្ងន់លើកាលានុវត្តភាពស្មើភាពគ្នាសម្រាប់គណៈបក្សនយោ បាយ ដោយគោរពតាមសមត្ថភាពរបស់ពួកគេ ក្នុងការទទួលបានមូលនិធិ និងការអនុវត្ត សិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់ពួកគេ រួមទាំងតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី។

៣៤.នៅក្នុងរបាយការណ៍តាមវិស័យលើកទី២របស់លោក(A/HRC/23/39)អ្នករាយការណ៍ពិសេសបានកំណត់លទ្ធភាពសមាគមក្នុងការទទួលបានធនធានហិរញ្ញវត្ថុថាជាកត្តារួមមួយនៃសិទ្ធិសេរីភាពខាងសមាគម។ បញ្ហាមូលនិធិមានផលវិបាកយ៉ាងធំធេងលើសិទ្ធិសេរីភាពសមាគម សំរាប់គណៈបក្សនយោបាយនៅក្នុងបរិបទនៃការបោះឆ្នោត។ ការផ្តល់មូលនិធិធ្វើឲ្យប្រាកដថាគណៈបក្សនយោបាយអាចមានលទ្ធភាពដំណើរការជាប្រចាំថ្ងៃចូលរួមក្នុងឆាកនយោបាយ តំណាងឲ្យពហុភាពនៃទស្សនៈ ផលប្រយោជន៍ និងទស្សនវិស័យ ដែលពង្រឹងដល់លទ្ធិប្រជាធិបតេយ្យ។ ការផ្តល់មូលនិធិអាចមានឥទ្ធិពលមិនល្អទៅលើសក្តានុពលលទ្ធិប្រជាធិបតេយ្យ ដែលតម្រូវឲ្យមានបទបញ្ញត្តិជាក់លាក់មួយចំនួន។ អ្នករាយការណ៍ពិសេសចែករំលែកទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្ស នៅក្នុងសេចក្តីពន្យល់ទូទៅលេខ២៥ (កថាខ័ណ្ឌទី១៩) ថាការដាក់កំហិតដ៏សមហេតុផលទៅលើការចំណាយយុទ្ធនាការអាចត្រូវបានធ្វើយុត្តិកម្មក្នុងករណីចាំបាច់ ដើម្បីធានាថា ជម្រើសដោយសេរីរបស់អ្នកបោះឆ្នោត មិនត្រូវបានធ្វើឲ្យអន្តរាយ ឬដំណើរការលទ្ធិប្រជាធិបតេយ្យមិនត្រូវបានបំភ្លៃ ដោយការចំណាយមិនសមាមាត្រ ក្នុងនាមបេក្ខជនណាម្នាក់ ឬគណៈបក្សណាមួយ។

៣៥. គោលការណ៍សំខាន់ៗមួយចំនួន អាចយកមកប្រើដើម្បីណែនាំដល់ការអភិវឌ្ឍន៍ និងប្រតិបត្តិការនៃវិធានហិរញ្ញវត្ថុសំរាប់គណៈបក្សនយោបាយ។ ការផ្តល់ហិរញ្ញប្បទានសាធារណៈសំរាប់គណៈបក្សនយោបាយ តែងតែត្រូវបានប្រើជាមធ្យោបាយមួយ ដើម្បីផ្តល់ឱកាសស្មើភាពដល់គណៈបក្សទាំងអស់ និងធានាការពារការចូលរួមប្រកួតប្រជែងនៃគំនិត និងទស្សនៈផ្សេងៗគ្នា។ សំខាន់បំផុតការផ្តល់មូលនិធិសាធារណៈ ផ្តល់ប្រយោជន៍ដល់គណៈបក្សដែលគ្មានលទ្ធភាពផ្សេងស្វែងរកមូលនិធិឯកជន សំរាប់ហេតុផលមួយចំនួនណានោះ រាប់ទាំងដោយសារពួកគេជាគណៈបក្សតូចៗឬដោយសារមនោគមវិជ្ជារបស់ពួកគេមិនអាចអំពាវនាវរកបាននូវសម្លេងភាគច្រើននៃម្ចាស់ជំនួយ ឬអ្នកទាំងឡាយដែលតំណាងឲ្យក្រុមជនងាយរងគ្រោះ ដូចជាស្ត្រី និងយុវជន។ ហេតុដូច្នេះ ការផ្តល់មូលនិធិសាធារណៈមិនត្រូវយកមកប្រើដើម្បីជ្រៀតជ្រែកដល់ឯករាជភាពរបស់គណៈបក្សនិងបង្កើនឬបង្កើតភាពពឹងអាស្រ័យច្រើនពេកទៅលើធនធានទាំងឡាយរបស់រដ្ឋ។[១៣]

៣៦. ក្នុងន័យទូលាយជាងនេះ ធនធានទាំងឡាយរបស់គណៈបក្សត្រូវញែកឲ្យដាច់ស្រឡះពីធនធានសាធារណៈ។ ធនធានសាធារណៈ មិនត្រូវបានយកមកប្រើ ដើម្បីធ្វើឲ្យទីលានប្រកួតប្រជែងបោះឆ្នោត ផ្អៀងទៅម្ខាង ក្នុងការគាំទ្រគណៈបក្សណាមួយ ជាពិសេស គណៈ

[១១]. អង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ុប / ការិយាល័យសំរាប់ស្ថាប័នលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងគណៈកម្មការវ៉ឺនីស គោលការណ៍ណែនាំស្តីពីវិធានគណៈបក្សនយោបាយ ឆ្នាំ២០១០ កថាខ័ណ្ឌទី១៧៦-១៧៧។

បក្សកាន់អំណាចឬបេក្ខជនរបស់គណៈបក្សកាន់អំណាចនោះទេ។ គោលការណ៍នេះពង្រីកវិសាលភាពដល់ការប្រើប្រាស់ស្ថាប័នរដ្ឋ ដូចជាកងកម្លាំងនគរបាល ស្ថាប័នតុលាការ ស្ថាប័នអយ្យការ ទីភ្នាក់ងារប្រតិបត្តិច្បាប់ និងស្ថាប័នផ្សេងៗទៀត ដែលត្រូវរក្សាអនាគតិនៅពេលត្រួតពិនិត្យ ឬដាក់កំហិតលើសកម្មភាពរបស់គណៈបក្សនយោបាយនានា ដូចជាការផ្តួចផ្តើមដាក់ពាក្យបណ្តឹងដោយហេតុផលនយោបាយប្រឆាំងនឹងបេក្ខជនគូប្រកួត ដែលតាមពិតទៅគឺដើម្បីរារាំងពួកគេមិនឲ្យចូលរួមក្នុងសកម្មភាពឃោសនា។

**៣៧.** ពហុនិយម គឺជាសញ្ញាសំគាល់នៃលទ្ធិប្រជាធិបតេយ្យ ដោយមានគណៈបក្សនយោបាយនានា ជាកាតាលីករ សំរាប់ការពិភាក្សាដេញដោល និងការសន្ទនា នៅក្នុងសង្គមប្រជាធិបតេយ្យ ដោយការពិភាក្សាដេញដោលបែបនេះ បង្កើតជាមូលដ្ឋាននៃការជ្រើសរើសអ្នកតំណាងរបស់ម្ចាស់ឆ្នោត។ តុលាការសិទ្ធិមនុស្សអឺរ៉ុបពិនិត្យឃើញថា មិនអាចមានប្រជាធិបតេយ្យដោយគ្មានពហុនិយមនោះទេ។ ដោយសារមូលហេតុដូច្នេះ សេរីភាពក្នុងការបញ្ចេញមតិ អាចអនុវត្តមិនចំពោះតែ "ព័ត៌មាន" ឬ "គំនិត" ដែលត្រូវបានគេទទួលយ៉ាងពេញចិត្ត ឬចាត់ទុកជាការមិនវាយប្រហារ ឬចាត់ទុកជាបញ្ហាមិនអើពើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចអនុវត្តចំពោះព័ត៌មាន និងគំនិតដែលវាយប្រហារ ធ្វើឲ្យតក់ស្លុត ឬធ្វើឲ្យរំខានផងដែរ។[១៤] នៅក្នុងសេចក្តីសម្រេចជាព្រឹត្តិការណ៍មួយទៀតតុលាការនេះបានរកឃើញការរំលោភបំពានទៅលើសេរីភាពខាងសមាគម ដោយលើកអំណះអំណាងថា ការរំលែកញែកអំពីមនសិការរបស់ក្រុមជនភាគតិច និងការអភិរក្សព្រមទាំងការអភិវឌ្ឍន៍វប្បធម៌របស់ក្រុមជនភាគតិច មិនអាចនិយាយថាជាការគំរាមកំហែងដល់ "សង្គមប្រជាធិបតេយ្យ" បានឡើយ បើទោះបីវាអាចបង្កភាពតានតឹងក៏ដោយ។ តុលាការបានលើកអំណះអំណាងបន្ថែមថា ការលេចឡើងនូវភាពតានតឹង គឺជាផលវិបាកមួយក្នុងចំណោមផលវិបាកនៃពហុនិយមទាំងឡាយ ដែលមិនអាចជៀសផុតបាន ជារួមចង់និយាយថា ជាការពិភាក្សាដោយសេរីនូវគ្រប់ទស្សនៈនយោបាយ។

**៣៨.** ហេតុដូច្នេះ គណៈបក្សនយោបាយមានសេរីភាពជ្រើសរើស និងប្រកាន់យកមនោគមវិជ្ជានានា ទោះបីជាមនោគមវិជ្ជាទាំងនេះ មិនមានប្រជាប្រិយ៍ភាពជាមួយអាជ្ញាធរ ឬសាធារណៈជនទូទៅក៏ដោយ រាប់ទាំងលទ្ធភាពអំពាវនាវឲ្យធ្វើពហិការមិនចូលរួមការបោះឆ្នោតផងដោយគ្មានការភ័យខ្លាចពីការសងសឹកសំរាប់ការធ្វើដូច្នេះ។ សេរីភាពក្នុងការបញ្ចេញមតិនិងគំនិតយោបល់របស់គណៈបក្សនយោបាយ ជាពិសេស តាមរយៈយុទ្ធនាការបោះឆ្នោត រាប់ទាំងសិទ្ធិស្វែងរកទទួលនិងផ្សព្វផ្សាយព័ត៌មាន គឺមានសារៈសំខាន់ចំពោះសុចរិតភាពនៃការ

---

[១៤] តុលាការសិទ្ធិមនុស្សអឺរ៉ុប ករណីរបស់ Handyside ទល់នឹងចក្រភពអង់គ្លេស កថាខ័ណ្ឌទី៤៩។

[១៥] តុលាការសិទ្ធិមនុស្សអឺរ៉ុប ករណីរបស់ Ouranio Toxo ទល់នឹងប្រទេសក្រិក សេចក្តីអនុវត្តលេខ៧៤៩៨៩/០១ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ កថាខ័ណ្ឌទី៤០។

បោះឆ្នោត។ អ្នករាយការណ៍ពិសេសរំលឹកថា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ១២/១៦ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបញ្ជាក់ច្បាស់ថា ជាគោលការណ៍ គ្មានការរិតត្បិតអាចត្រូវបានអនុញ្ញាតទាក់ទងនឹង ដូចជា ការពិភាក្សាអំពីគោលនយោបាយរដ្ឋាភិបាល និងការពិភាក្សាដេញដោលខាងនយោបាយ សេចក្តីរាយការណ៍អំពីសិទ្ធិមនុស្ស សកម្មភាពរដ្ឋាភិបាលនិងអំពើពុករលួយក្នុងរដ្ឋាភិបាល ការចូលរួមក្នុងយុទ្ធនាការបោះឆ្នោត ការធ្វើបាតុកម្មដោយសន្តិវិធី ឬសកម្មភាពនយោបាយ រាប់ទាំងសំរាប់សន្តិភាពឬលទ្ធិប្រជាធិបតេយ្យ និងការសម្តែងមតិយោបល់ស្រប និងមតិយោបល់ជំទាស់ សាសនាឬជំនឿ រាប់ទាំងតាមរយៈបុគ្គលនៃក្រុមជនភាគតិចឬក្រុមជនងាយរងគ្រោះ។ អ្នករាយការណ៍ពិសេសសង្កត់ធ្ងន់ថា លុះត្រាតែនៅពេលណាគណៈបក្សនយោបាយមួយ ឬបេក្ខជនណាមួយរបស់គណៈបក្សនោះ ប្រើអំពើហិង្សា ឬតស៊ូមតិឲ្យប្រព្រឹត្តអំពើហិង្សា ឬប្រព្រឹត្តអំពើស្អប់ខ្ពើមជាតិសាសន៍ សាសនា ឬពូជសាសន៍ ដែលចូលជាបទល្មើសញុះញង់ឲ្យមានការរើសអើង អរិភាព ឬអំពើហិង្សា (មាត្រា ២០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ដូចបានឆ្លុះបញ្ចាំងផងដែរក្នុងមាត្រា៥ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍)[១៦] ឬលុះត្រាតែនៅពេលណាគណៈបក្សនោះ ធ្វើសកម្មភាពឬអំពើទាំងឡាយដែលមានគោលដៅបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាព ដែលបានតម្កល់ទុកក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ(មាត្រា៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ) ប៉ុណ្ណោះ ទើបគណៈបក្សនយោបាយនោះ អាចត្រូវបានហាមឃាត់តាមផ្លូវច្បាប់។

**៣៩.** ចំណុចស្នូលនៃសេរីភាពក្នុងការបញ្ចេញមតិរបស់គណៈបក្សនយោបាយ គឺជាឱកាសសំរាប់ឲ្យពួកគេមានសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយស្មើភាពគ្នា ជាពិសេសប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ឬដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ។ ច្បាប់ត្រូវកំណត់ក្របខ័ណ្ឌច្បាស់លាស់មួយ សំរាប់ការអនុវត្តសិទ្ធិប្រើប្រាស់ស្មើភាពគ្នានូវប្រព័ន្ធផ្សព្វផ្សាយ រាប់ទាំងក្នុងកំឡុងពេលយុទ្ធនាការ។ ឧទាហរណ៍ គ្រប់គណៈបក្សដែលបង្ហាញបេក្ខជនសំរាប់ការបោះឆ្នោត មានសិទ្ធិប្រើប្រាស់សេវាផ្សព្វផ្សាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ហើយក្នុងបរិបទនេះ ការផ្តល់ពេលវេលាផ្សព្វផ្សាយដោយសេរី ធានាថាគ្រប់គណៈបក្សនយោបាយទាំងអស់ រាប់ទាំងគណៈបក្សតូចៗផង អាចមានលទ្ធភាពផ្សព្វផ្សាយទស្សនៈនិងគំនិតយោបល់របស់ខ្លួន។[១៧] ការផ្តល់ពេលវេលាផ្សព្វផ្សាយមុនពេលបោះឆ្នោត ត្រូវធ្វើដោយស្មើៗគ្នា ផ្អែកតាមគោល

---

[១៦]. សូមមើលគេហទំព័រ៖ http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=13584&LangID=E

[១៧]. អង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ុប / ការិយាល័យសំរាប់ស្ថាប័នលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងគណៈកម្មការវ៉េនីស។ គោលការណ៍ណែនាំស្តីពីវិធានគណៈបក្សនយោបាយ ឆ្នាំ២០១១ កថាខ័ណ្ឌទី១៤៧។

ការណ៍ស្ដីពីសមភាពចំពោះមុខច្បាប់ និងគោលការណ៍មិនរើសអើង។ ការបដិសេធសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈរបស់គណៈបក្សជាក់លាក់ទាំងឡាយ ឬការផ្ដល់សេវាផ្សព្វផ្សាយដោយលំអៀង ជាអាទិ៍ ផ្អែកលើការមិនទទួលយកគណៈបក្សណាមួយ ឬទស្សនៈរបស់បេក្ខជនណាម្នាក់ គឺមិនស្របទៅនឹងសិទ្ធិសេរីភាពខាងសមាគម និងការបញ្ចេញមតិឡើយ។ត្រូវយកចិត្តទុកដាក់ចំពោះភាពខុសគ្នារវាងសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងនាមគណៈបក្សនយោបាយ និងសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងនាមមន្ត្រីរដ្ឋ ដោយសារតែជាសក្ដានុពលដល់គុណសម្បត្តិមិនត្រឹមត្រូវ ដែលកើតចេញពីគណៈបក្សនយោបាយកាន់អំណាច ប្រើប្រាស់សេវាប្រព័ន្ធផ្សព្វផ្សាយពីភារកិច្ចផ្លូវការរបស់ខ្លួនជាវេទិកាយុទ្ធនាការ។

**៤០.** ចាប់តាំងពីការចាប់ផ្ដើមអាណត្តិការងាររបស់លោក អ្នករាយការណ៍ពិសេសបានទទួលការចោទប្រកាន់ជាច្រើនចំពោះការពិតដែលថា នៅកំឡុងពេលបោះឆ្នោត អ្នកដឹកនាំនយោបាយ និងអ្នកគាំទ្រ ជាពិសេសមកពីគណៈបក្សប្រឆាំងប្រឈមនឹងហានិភ័យកំរិតខ្ពស់។ នៅមុនពេល នៅអំឡុងពេល និងនៅក្រោយពេលបោះឆ្នោត អ្នកទាំងឡាយណាដែលសម្ដែង ឬបានសម្ដែងយោបល់ជំទាស់ ត្រូវទទួលរងនូវការរុកគួន ការបំភិតបំភ័យ ការប៉ុនប៉ងប្រព្រឹត្តអំពើពុករលួយ ការសងសឹក ការចាប់ខ្លួននិងការដាក់ពន្ធនាគារតាមទំនើងចិត្ត ដោយសារតែមតិយោបល់ខាងនយោបាយ ឬជំនឿរបស់ពួកគេតែប៉ុណ្ណោះនៅក្នុងប្រទេសជាច្រើន។ ក្នុងទិដ្ឋភាពនេះ អ្នករាយការណ៍ពិសេស មានសេចក្ដីកង្វល់អំពីករណីនៃមេដឹកនាំប្រឆាំងមួយរូបពីប្រទេសបេលឡារុសដែលត្រូវទទួលរងនូវការកាត់ទោសយ៉ាងធ្ងន់ធ្ងរក្នុងឆ្នាំ២០១១ បន្ទាប់ពីគាត់បានចូលរួមក្នុងការប្រមូលផ្ដុំមួយតវ៉ានឹងលទ្ធផលបោះឆ្នោតប្រធានាធិបតីនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១។ នៅសាធារណៈរដ្ឋឥស្លាមអ៊ីរ៉ង់ មានការសម្ដែងនូវកង្វល់ទាក់ទងនឹងអតីតបេក្ខជនប្រធានាធិបតីជាច្រើនរូប ដែលបានធ្វើការប្រមូលផ្ដុំក្នុងស្មារតីសាមគ្គីភាពជាមួយអ្នកតវ៉ានៅប្រទេសអេហ្ស៊ីប ដែលពួកគេបានស្វែងរកការអនុញ្ញាតពីអាជ្ញាធរ ហើយពួកគេត្រូវបានឃុំខ្លួនតែនៅក្នុងផ្ទះរបស់ពួកគេ "ដោយកាត់ផ្ដាច់ទំនាក់ទំនងពីប្រភពខាងក្រៅ" ចាប់តាំងតែពីខែកុម្ភៈ ឆ្នាំ២០១១។

**៤១.** គណៈបក្សនយោបាយ និងសមាជិករបស់ខ្លួន ដែលត្រូវបានរិតត្បិតមិនសមហេតុផលពីការអនុវត្តសិទ្ធិសមាគមដោយសេរី គួរមានសិទ្ធិប្ដឹងរកដំណោះស្រាយភ្លាម និងមានប្រសិទ្ធភាព។ ជាថ្មីម្ដងទៀត អ្នករាយការណ៍ពិសេសសង្កត់ធ្ងន់ថា រដ្ឋមានកាតព្វកិច្ចផ្ដល់នូវស្ថាប័នដែលមិនលំអៀងនិងឯករាជ រួមទាំងស្ថាប័នគ្រប់គ្រងការបោះឆ្នោត និងអាជ្ញាធរគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយបន្ថែមទៅលើស្ថាប័នតុលាការឯករាជ ដើម្បីធានាថាដំណើរការបោះឆ្នោតមិនត្រូវបានកេងប្រវ័ញ្ច បើមិនដូច្នោះទេ បង្កើតឲ្យមានទីលានប្រកួតប្រជែងមិនស្មើភាពមួយសំរាប់គណៈបក្សនយោបាយមួយចំនួន។ ដើម្បីឲ្យមានប្រសិទ្ធភាព ស្ថាប័នមានអំណាចធ្វើ

បទបញ្ញាត្រូវតែឯករាជពីអំណាចនីតិប្រតិបត្តិ ត្រូវផ្តល់អំណាច និងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីតាក់តែង ឃ្លាំមើល និងដាក់ឲ្យប្រតិបត្តិនូវបទបញ្ញា/បទបញ្ញត្តិទាំងឡាយ។ ទាំងនេះគឺជាល័ក្ខខ័ណ្ឌចម្បង សំរាប់ធានាឲ្យមានការគោរពសិទ្ធិសេរីភាពខាងសមាគម ក្នុងបរិបទនៃការបោះឆ្នោត។

## *ខ. អង្គការសង្គមស៊ីវិល*

៤២. អង្គការសង្គមស៊ីវិលដើរតួនាទីសំខាន់ផងដែរ នៅក្នុងបរិបទនៃការបោះឆ្នោត។ តួនាទីអង្គការសង្គមស៊ីវិលក្នុងការរួមចំណែកដល់ និងធ្វើឲ្យមាននិរន្តរភាពដល់លទ្ធិប្រជាធិបតេយ្យដ៏រឹងមាំមួយ មិនអាចត្រូវបានមើលស្រាលនោះទេ។ តាមសមត្ថភាពផ្សេងៗគ្នា អង្គការសង្គមស៊ីវិលធ្វើសកម្មភាពផ្សេងៗ ដើម្បីតស៊ូមតិសំរាប់សេចក្តីកង្វល់ និងផលប្រយោជន៍ដល់អ្នកទទួលផល រួមចំណែកធានាឲ្យមានសុចរិតភាពនៃដំណើរការបោះឆ្នោត រួមចំណែកបន្ថែមទៀតដល់សមិទ្ធផលការការពារនិងការពង្រឹងបទដ្ឋាននិងគោលដៅប្រជាធិបតេយ្យនិងដាក់ឲ្យអាជ្ញាធរ ទទួលខុសត្រូវចំពោះមុខម្ចាស់ឆ្នោត។ ក្នុងចំណោមកិច្ចការដទៃទៀត អង្គការសង្គមស៊ីវិលលើកស្ទួយការចូលរួមនយោបាយ ធ្វើការអប់រំម្ចាស់ឆ្នោត ធ្វើយុទ្ធនាការឱ្យមានការកែទម្រង់អភិបាលកិច្ចល្អ ផ្តល់មធ្យោបាយដល់ការសម្តែងផលប្រយោជន៍ផ្សេងៗ ថែមទាំងដើរតួនាទីជាវេទិកាដែលឆ្លងកាត់នូវឧបសគ្គកុលសម្ព័ន្ធ ជាតិពន្ធុ ភាសា និងឧបសគ្គដទៃទៀតនិងធ្វើជាចលករដល់ការពិភាក្សាដេញដោលលើបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ។

៤៣. អ្នករាយការណ៍ពិសេសសង្កត់ធ្ងន់ថា សិទ្ធិសេរីភាពខាងសមាគម តម្រូវជាចាំបាច់ឲ្យមានសេរីភាពខាងសមាគមសម្រេចនិងចូលរួមក្នុងសកម្មភាពទាំងឡាយតាមការជ្រើសរើសដោយផ្ទាល់របស់ខ្លួន ហើយសេរីភាពនេះ ពង្រីកវិសាលភាពដល់អ្នកទាំងឡាយណាដែលប្រាថ្នាចង់ចូលរួមក្នុងសកម្មភាពទាក់ទងនឹងការបោះឆ្នោត។ ហេតុដូច្នេះ ក្នុងចំណោមសេរីភាពដទៃទៀត សមាគមមានសេរីភាពតស៊ូមតិ សំរាប់កំណែទម្រង់គោលនយោបាយទូលំទូលាយ និងកំណែទម្រង់ការបោះឆ្នោត ដើម្បីពិភាក្សាបញ្ហានៃកង្វល់ជាសាធារណៈ និងរួមចំណែកដល់ការពិភាក្សាដេញដោលជាសាធារណៈ តាមឃ្លាំមើល និងសង្កេតមើលដំណើរការបោះឆ្នោត រាយការណ៍អំពីការរំលោភសិទ្ធិមនុស្សនិងការលួចបន្លំឆ្នោត ផ្តួចផ្តើមការស្ទង់មតិនិងការបោះឆ្នោត ដូចជា ការស្ទង់មតិដែលត្រូវធ្វើឡើងនៅអំឡុងពេលដំណើរការបោះឆ្នោត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយសេរី រួមទាំងប្រព័ន្ធផ្សព្វផ្សាយថ្មីៗ ដូចជាអ៊ិនធើណិត ដើម្បីស្វែងរក ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតយោបល់គ្រប់ប្រភេទដោយគ្មានព្រំដែន ទោះផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬតាមអនឡាញក្តី កសាងសម្ព័ន្ធភាពនិងបណ្តាញជាមួយអង្គការដទៃទៀត រួមទាំងអង្គការមកពីបរទេស ចូលរួមក្នុងសកម្មភាព

ស្វែងរកមូលនិធិ ចូលរួមសង្កេតការបោះឆ្នោត ការអប់រំម្ចាស់ឆ្នោត និងពិនិត្យមើលបញ្ជីអ្នកបោះឆ្នោត ធ្វើអន្តរកម្មជាមួយស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ និងតំបន់ និងផ្តល់ជំនួយបច្ចេកទេស និងកិច្ចសហការអន្តរជាតិតាមទម្រង់ណាមួយ។

៤៤. អង្គការសង្គមស៊ីវិល មានភាពខុសគ្នាតាំងពីកំណើត ពីគណៈបក្សនយោបាយ ដែលគោលដៅចុងក្រោយរបស់ពួកគេ គឺលើកស្ទួយបេក្ខជនដែលនឹងឈរឈ្មោះបោះឆ្នោតសំដៅដឹកនាំប្រទេស។ ដូច្នេះបទបញ្ញានិងការរិតត្បិតផ្សេងត្រូវយកមកអនុវត្តចំពោះអង្គការសង្គមស៊ីវិល។ ស្របនឹងបរិបទនេះ សមាគមមិនត្រូវបានបង្ខំឲ្យចុះបញ្ជីជាគណៈបក្សនយោបាយឡើយ ហើយផ្ទុយទៅវិញ សមាគមក៏មិនត្រូវបានបដិសេធមិនឲ្យចុះបញ្ជីជាសមាគមដោយសារតែពួកគេធ្វើអ្វីៗដែលអាជ្ញាធរចាត់ទុកថាជាសកម្មភាព"នយោបាយ"ដែរ។វាជាប្រភពនៃសេចក្តីកង្វល់ធ្ងន់ធ្ងរដែលថា ពាក្យ "នយោបាយ" ត្រូវបានបកស្រាយក្នុងន័យមួយទូលាយនៅតាមបណ្តាប្រទេសជាច្រើន ដើម្បីក្តោបសកម្មភាពតស៊ូមតិគ្រប់ប្រភេទ ការអប់រំពលរដ្ឋការស្រាវជ្រាវ ហើយទូទៅជាងនេះ សកម្មភាពទាំងឡាយដែលមានគោលដៅជះឥទ្ធិពលលើគោលនយោបាយសាធារណៈឬទស្សនៈសាធារណៈ។វាច្បាស់ណាស់ថាការបកស្រាយនេះត្រូវបានជំរុញតាមតែសេចក្តីត្រូវការ ដើម្បីទប់ស្កាត់មិនឲ្យមានការរិះគន់តាមទម្រង់ណាមួយប៉ុណ្ណោះ។ នៅក្នុងបរិបទនេះ មានការសម្តែងក្តីបារម្ភអំពីស្ថានភាពនៅសហព័ន្ធរុស្ស៊ី ជាទីដែលអង្គការសិទ្ធិមនុស្សមួយបានក្លាយជាកម្មវត្ថុនៃការត្រួតពិនិត្យពីមហាអយ្យការ ដែលអះអាងថា អង្គការនេះ បានចូលរួម "សកម្មភាពនយោបាយ" តាមរយៈ "ការប្រើប្រាស់ឥទ្ធិពលដោយចេតនាទៅលើមុខមាត់នៃគណៈកម្មការបោះឆ្នោត និងអង្គការរដ្ឋដទៃទៀត តាមរយៈការចូលរួមក្នុងដំណើរការបោះឆ្នោត" បន្ទាប់ពីសមាជិកមួយចំនួននៃអង្គការនេះបានអះអាងពីភាពមិនប្រក្រតី នៅអំឡុងពេលបោះឆ្នោត ខែធ្នូ ឆ្នាំ២០១១។ អ្នករាយការណ៍ពិសេសរំលឹកថា សិទ្ធិសេរីភាពខាងសមាគមគឺជាសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលជួយសម្រួលដល់ការចូលរួមពីគ្រប់មជ្ឈដ្ឋាន ក្នុងការធ្វើសេចក្តីសម្រេចនៃកិច្ចការសាធារណៈ។ សេរីភាពខាងសមាគមផ្តល់ឱកាសតែមួយគត់ដល់បុគ្គល ឱ្យសម្តែងមតិនយោបាយរបស់ខ្លួន និងចូលរួមក្នុងសកម្មភាពសង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌។ តាមពិត សមាគមដែលត្រូវបានចោទប្រកាន់ពីការចូលរួមសកម្មភាព"នយោបាយ"ជាញឹកញាប់ គឺជាសមាគមដែលព្យាយាមដាក់រដ្ឋាភិបាលឲ្យទទួលខុសត្រូវ តាមរយៈអភិបាលកិច្ចល្អ និងការផ្តួចផ្តើមគំនិតនៃនីតិរដ្ឋ ដូចជាវិធានការប្រឆាំងអំពើពុករលួយ យុទ្ធនាការសិទ្ធិមនុស្ស កំណែទម្រង់ស្ថាប័ន និងវិធានការស្រដៀងគ្នានេះដែលត្រូវបានរៀបចំឡើងដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ។ អ្នករាយការណ៍ពិសេសយល់ឃើញថា ការលាបពណ៌សមាគមជា "នយោបាយ" ហើយឈរលើមូលដ្ឋាននោះ ដោយភ្ជាប់ពួកគេទៅនឹងគណៈបក្សប្រឆាំង ឬរារាំងពួកគេមិនឲ្យធ្វើប្រតិបត្តិការ គឺភាគច្រើនមានបំណងបំបិទសម្លេង ដែលរិះគន់ការអនុវត្ត និងគោលនយោបាយរដ្ឋាភិបាល។

 

**៤៥.** ថ្វីត្បិតតែអង្គការសង្គមស៊ីវិលដើរតួនាទីសំខាន់នៅអំឡុងពេលបោះឆ្នោតក្តី ក៏សេរីភាពខាងសមាគម ត្រូវបានរិតត្បិតនៅមុនពេល អំឡុងពេល និងនៅក្រោយពេលបោះឆ្នោត ក្នុងប្រទេសជាច្រើន។ ដូចដែលអ្នករាយការណ៍ពិសេស បានកត់សំគាល់អំពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស អំពើបំភិតបំភ័យប្រឆាំងនឹងសកម្មជនស៊ីវិល តែងតែចាប់ផ្តើមកើតឡើងរយៈពេលយូរ មុនពេលចាប់ផ្តើមយុទ្ធនាការបោះឆ្នោត (A/HRC/13/22 para. 56) ការរិតត្បិតលើសមាគមដែលមិនបានចុះបញ្ជី ដោយរារាំងពួកគេមិនឲ្យចូលរួមសកម្មភាពទាក់ទងនឹងដំណើរការបោះឆ្នោត គឺជាមធ្យោបាយមួយរាំងខ្ទប់ការងារនៃសម្លេងឯករាជ។ ដូចដែលអ្នករាយការណ៍ពិសេសបានអះអាងក្នុងរបាយការណ៍មុនៗ សិទ្ធិសេរីភាពខាងសមាគម ត្រូវយកមកអនុវត្តឱ្យស្មើភាពគ្នាចំពោះសមាគមដែលមិនបានចុះបញ្ជី (A/HRC/20/27, para. 56)។ ដោយសារតែការផាត់ចេញ ស្រ្តី យុវជន អប្បភាគជន ក្រុមជនជាតិដើមភាគតិច ឬជនពិការអាចបង្កើត ឬចូលរួមសមាគមដែលមិនបានចុះបញ្ជីដើម្បីភាពជឿនលឿននៃផលប្រយោជន៍របស់ខ្លួន។ រដ្ឋត្រូវដើរតួនាទីយ៉ាងសកម្ម ក្នុងការដកចេញនូវឧបសគ្គនានា ដែលរារាំងក្រុមងាយជនរងគ្រោះ និងក្រុមមនុស្សគ្មានអំណាច មិនឲ្យចូលរួមក្នុងជីវភាពសាធារណៈ និងការអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងបរិបទនៃការបោះឆ្នោត។ ប្រការនេះមានសារៈសំខាន់ដើម្បីធានាថា សម្លេងរបស់ពួកគេត្រូវបានឮ ហើយបុព្វហេតុរបស់ពួកគេត្រូវបានពិចារណានៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាលអាណត្តិក្រោយ។

**៤៦.** ហេតុដូច្នេះ សេរីភាពខាងសមាគមចូលរួមសកម្មភាពទាក់ទងនឹងដំណើរការបោះឆ្នោតត្រូវបានធានាការពារដល់គ្រប់សមាគម ទោះបីជាសមាគមទាំងនេះនៅក្រៅនយោបាយ តាមរយៈមធ្យោបាយនិងប្រតិបត្តិការរបស់ពួកគេដែលគាំទ្រដល់រដ្ឋាភិបាលមួយផ្នែកឬទាំងស្រុងឬទោះបីសម្តែងនូវការរិះគន់គោលនយោបាយរដ្ឋាភិបាលក៏ដោយ។ដូច្នេះគ្មានសមាគមណាមួយ ត្រូវបានបង្ខំឲ្យសម្តែងការគាំទ្របេក្ខជនឈរឈ្មោះបោះឆ្នោតណាម្នាក់ឡើយ។ ទោះបីយ៉ាងណាក៏ដោយ វាមានសារៈសំខាន់សំរាប់អង្គការណាមួយ ដែលគាំទ្របេក្ខជនពិសេសណាម្នាក់ដោយស្ម័គ្រចិត្តឬគណៈបក្សណាមួយនៅក្នុងការបោះឆ្នោត ត្រូវធ្វើឱ្យមានតម្លាភាពក្នុងការប្រកាសពីហេតុផលរបស់ខ្លួន ដោយសារតែការគាំទ្ររបស់ខ្លួន អាចមានឥទ្ធិពលទៅលើលទ្ធផលនៃការបោះឆ្នោត។ អ្នករាយការណ៍ពិសេសយល់ឃើញថា ចំណុចខ្លាំងនៃលទ្ធិប្រជាធិបតេយ្យ ត្រូវបានវាស់វែងតាមកម្រិតមួយដែលទស្សនៈចម្រុះ និងមតិយោបល់ផ្សេងគ្នាត្រូវបានទទួលយក ហើយកាន់តែលើកទឹកចិត្តថែមទៀត នៅក្នុងការពិភាក្សាដេញដោលជាសាធារណៈ។

**៤៧.** សិទ្ធិសេរីភាពខាងសមាគម គឺជាសមាសភាគសំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យដែលផ្តល់អំណាចដល់ស្ត្រី និងបុរស ហើយអាស្រ័យហេតុនេះ វាមានសារៈសំខាន់ពិសេស ដែលបុគ្គលទាំងឡាយ អាចគាំទ្រអប្បភាគជន ឬក្រុមជំនឿនយោបាយ ឬសាសនាបែបប្រឆាំង (បុព្វកថានៃសេចក្តីសម្រេចក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ១៥/២១) ។ អាស្រ័យដូចបានរៀបរាប់ខាងលើ គ្មានការរឹតត្បិតណាមួយត្រូវបានធ្វើឡើងចំពោះសមាគម ដោយគ្រាន់តែសមាគមទាំងនេះ មិនមានទស្សនៈដូចគ្នាទៅនឹងទស្សនៈរបស់អាជ្ញាធរនោះឡើយ។

**៤៨.**រដ្ឋាភិបាលនៅប្រទេសជាច្រើនកំពុងតែដាក់ការរឹតត្បិតកាន់តែខ្លាំងឡើងៗលើលទ្ធភាពរបស់សង្គមស៊ីវិលក្នុងការចូលរួមបង្កើតឲ្យមានយន្តការប្រជាធិបតេយ្យ យុត្តិធម៌ប្រកបដោយតម្លាភាព និងគណនេយ្យភាព និងការរឹតត្បិតផងដែរដល់ការធ្វើសកម្មភាព ដូចជាឃ្លាំមើលការបោះឆ្នោត និងការកៀងគរអ្នកបោះឆ្នោតជាដើម។ ឧបសគ្គនានា រួមមាន ការហាមឃាត់ចំពោះក្រុមជាក់លាក់មួយចំនួន ដើម្បីចុះបញ្ជីសមាគម ការហាមឃាត់នូវការអនុវត្តសកម្មភាពការងារមួយចំនួន ដែលបញ្ជីហាមឃាត់នៃសកម្មភាពដែលត្រូវអនុញ្ញាតនោះ មិនមានកំណត់ដោយក្របខណ្ឌច្បាប់ទេ កាតព្វកិច្ចអនុម័តការលាបពណ៌ជាអវិជ្ជមាន ការបដិសេធនៃការទទួលស្គាល់ជាផ្លូវការដល់សមាគមក្នុងការឃ្លាំមើល និងសង្កេតការណ៍ការបោះឆ្នោត ឬថែមទាំងការដាក់ទណ្ឌកម្មឬការគំរាមកំហែងពីការដាក់ទណ្ឌកម្មចំពោះការចូលរួមក្នុងសកម្មភាពនានាដែលទាក់ទងនឹងដំណើរការបោះឆ្នោត។ អនុលោមទៅតាមបទដ្ឋានអន្តរជាតិត្រូវបានវិភាគស៊ីជម្រៅ នៅក្នុងរបាយការណ៍តាមវិស័យលើកទីពីររបស់អ្នករាយការណ៍ពិសេសដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស(A/HRC/23/39) នៅសហព័ន្ធរុស្ស៊ី ការអនុវត្តច្បាប់វិសោធនកម្ម ដែលមានការណែនាំ ឆ្នាំ២០១២ ចំពោះច្បាប់នីតិបញ្ញត្តិមួយចំនួនរបស់សហព័ន្ធរុស្ស៊ីទាក់ទងនឹងនិយតកម្មនៃសកម្មភាពរបស់អង្គការមិនមែនពាណិជ្ជកម្ម បំពេញមុខងាររបស់ភ្នាក់ងារបរទេស បាននាំឱ្យមានការធ្វើសវនកម្ម និងយុទ្ធនាការត្រួតពិនិត្យប្រឆាំងនឹងអង្គការសង្គមស៊ីវិលជាច្រើនដែលបានធ្វើ "សកម្មភាពនយោបាយ" ហើយបានខកខានក្នុងការចុះបញ្ជីជា "ភ្នាក់ងារបរទេស"។ សមាគមមួយក្នុងចំណោមសមាគមទាំងនោះ គឺសមាគមGolos សម្រាប់ការពារសិទ្ធិរបស់អ្នកបោះឆ្នោតគេហទំព័រអ៊ីនធឺណែតរបស់ខ្លួនត្រូវបានលួចចូលប្រើនៅមុនការឈានមកដល់នៃការបោះឆ្នោតសភា នៅខែមេសា ឆ្នាំ២០១៣ គឺជាអង្គការទី១ដែលត្រូវបានដាក់ទោសទណ្ឌនៅក្រោមច្បាប់ថ្មីនេះ។

**៤៩.** ដូចបានបរិយាយនៅក្នុងរបាយការណ៍មុនៗ របស់អ្នករាយការណ៍ពិសេសដែរ ការរឹតត្បិតណាមួយត្រូវតែបានអនុញ្ញាតដោយច្បាប់អន្តរជាតិ ហើយដូច្នេះ បំពេញបានតាមលក្ខខណ្ឌតម្រូវដ៏តឹងរឹងនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ នៅក្នុងបរិបទនៃការបោះឆ្នោត អ្នករាយការណ៍ពិសេសជឿជាក់ថា ព្រំដែននៃការសាកល្បងនេះគួរតែត្រូវបានដាក់ឱ្យនៅកម្រិតខ្ពស់

ជាងនេះ។ ដូច្នេះ វាមិនគ្រប់គ្រាន់សម្រាប់រដ្ឋមួយសំអាងតែទៅលើការការពារសុចរិតភាពនៃដំណើរការបោះឆ្នោត តម្រូវការធានាការបោះឆ្នោតដោយមិនលំអៀង និងគ្មានបក្ខពួកនិយម តម្រូវការរក្សាសន្តិភាព ឬសន្តិសុខដើម្បីកំរិតសិទ្ធិទាំងនេះ ដោយសារតែបរិបទនៃការបោះឆ្នោតគឺជាពេលដ៏សំខាន់មួយដែលបុគ្គលទាំងឡាយមានពាក្យកំណត់ពីជោគវាសនាប្រទេសរបស់ពួកគេ។ ក្នុងន័យនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថា សេចក្តីយោងដល់ "សង្គមប្រជាធិបតេយ្យ" នៅក្នុងបរិបទនៃមាត្រា២២គួសបង្ហាញនៅក្នុងយោបល់របស់គណៈកម្មាធិការថា អត្ថិភាព និងប្រតិបត្តិការសមាគម រួមទាំងសមាគមទាំងឡាយណាដែលលើកកម្ពស់គំនិតដោយសន្តិវិធីដែលមិនចាំបាច់ត្រូវបានត្រួតពិនិត្យដោយពេញចិត្តពីរដ្ឋាភិបាលឬមតិភាគច្រើននៃប្រជាជនឡើយ គឺជាស្នូលនៃសង្គមប្រជាធិបតេយ្យ។[១៨]

**៥០.** ក្នុងករណីមួយចំនួន មិនមានការជ្រៀតជ្រែកពីរដ្ឋនោះទេនៅពេលបង្កើតសមាគមមួយ ប៉ុន្តែមាននៅពេលដែលសមាគមនោះអនុវត្តសកម្មភាពរបស់ខ្លួន។ ជាញឹកញាប់ ការរិតត្បិតកើតឡើង នៅពេលដែលអាជ្ញាធរប្រឈមមុខនឹងទស្សនៈរបស់ជនភាគតិច ឬមតិជំទាស់ ឬសូម្បីតែនៅពេលដែលអាជ្ញាធរភ័យខ្លាចពីការដាក់ឲ្យទទួលខុសត្រូវ ចំពោះការខកខានរបស់ ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស។ នៅប្រទេសហ្ស៊ីមបាវេ ការិយាល័យនៃបណ្តាញគាំទ្រការបោះឆ្នោត ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលចំនួន៣១ បង្កើតឡើងនៅឆ្នាំ២០០០ ដើម្បីលើកកម្ពស់ការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ត្រូវបានគេឆែកឆេរតាមទំនើងចិត្តផ្អែកលើមូលដ្ឋានចោទប្រកាន់ថា អង្គការនេះមាន "សម្ភារៈ ឯកសារ ឧបករណ៍ ឬការថតសម្លេងដែលបង្កវិទ្ធង្សានា ហើយផ្ទុយនឹងច្បាប់អន្តោរប្រវេសន៍"។ ភ្នាក់ងារអង្គការសង្គមស៊ីវិលយល់ថា ការឆែកឆេរទាំងនេះ គឺជាការប៉ុនប៉ងមួយដើម្បីបំភិតបំភ័យ និងបំបិទមាត់របស់ពួកគេ នៅក្នុងបរិបទនៃការធ្វើប្រជាមតិ និងការបោះឆ្នោតឆ្នាំ២០១៣។

**៥១.** វាជាការអុកឡុកដែលថា នៅក្នុងបរិបទនៃការបោះឆ្នោត រដ្ឋមួយចំនួនប្រើប្រាស់ការបំភិតបំភ័យ ការរុកគួន បទបរិហារកេរ្តិ៍ជ្ឈប្បវេណីនិងព្រហ្មទណ្ឌ ឬការគំរាមកំហែងប្រឆាំងនឹងមេដឹកនាំសមាគម ដែលមានបំណងសម្តែងមតិ និងការឈឺចាប់ និងសេចក្តីប្រាថ្នារបស់ខ្លួន។ អ្នករាយការណ៍ពិសេសម្តែងក្តីបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពដូចខាងក្រោមនេះ ដែលបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាក់ទងទៅនឹងសេរីភាពខាងសមាគមត្រូវបានរំលោភបំពាន។ នៅប្រទេសម៉ាឡេស៊ី មេដឹកនាំម្នាក់នៃសម្ព័ន្ធសម្រាប់ការបោះឆ្នោតសេរី និងត្រឹមត្រូវដែលបានឃ្លាំមើលការបោះឆ្នោតនៅឆ្នាំ២០១៣ នៅក្នុងប្រទេស គឺជាគោលដៅនៃអំពើរុកគួនបំភិតបំភ័យដែលធ្ងន់ធ្ងរ និងដដែលៗ ហើយយុទ្ធនាការបង្ខូចឈ្មោះ ដែលបរិយាយអំពីនាង

[១៨] គណៈកម្មាធិការសិទ្ធិមនុស្ស ករណីលោក Boris Zvozskov និងអ្នកដទៃទៀត ទល់នឹងប្រទេសបេឡារុស(២០០១) CCPR/C/៨៨/D/១០៣៩/២០០១ កថាខណ្ឌ ៧.២ ។

ថាជា "សត្រូវដែលព្យាយាមបង្ខូចឈ្មោះរបស់ប្រទេសនេះ"។ នៅប្រទេសនីការ៉ាហ្គ័រ អ្នកការពារសិទ្ធិមនុស្សសកម្មក្នុងការងារសមាគម ដែលបានសម្តែងការព្រួយបារម្ភពីសេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញដែលអនុញ្ញាតឱ្យមានការបោះឆ្នោតប្រធានាធិបតីឡើងវិញ ត្រូវបានរាយការណ៍ថា បានទទួលរងនូវការគំរាមសម្លាប់ ការវាយប្រហារ និងអំពើបំភិតបំភ័យ។ នៅក្នុងប្រទេសរ៉្វាន់ដា អង្គការសម្ព័ន្ធក្នុងតំបន់ដែលធ្វើការលើបញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ ត្រូវបានរាយការណ៍ថា បានជួបប្រទះនឹងការគំរាមកំហែង និងការបំភិតបំភ័យ បន្ទាប់ពីអង្គការនេះ បានចេញផ្សាយរបាយការណ៍ដ៏ចម្រូងចម្រាស់មួយ ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសអង្គនីតិបញ្ញត្តិ។

៥២. ក្នុងករណីដទៃទៀត សកម្មជនសង្គមស៊ីវិលបានប្រឈមមុខនឹងការឃុំខ្លួនតាមទំនើងចិត្ត និងជាប់ពន្ធនាគាររយៈពេលយូរ បន្ទាប់ពីសវនាការមិនត្រឹមត្រូវ។ នៅប្រទេសបេឡារុសមានការវាយឆ្មក់ចូលផ្ទះ និងការិយាល័យជាច្រើនលើកច្រើនសារ ការចាប់ខ្លួន ការកាត់ទោស និងការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សជាច្រើននាក់ដែលសកម្មនៅក្នុងសមាគមស៊ីវិល ជាលទ្ធផលនៃសកម្មភាពសិទ្ធិមនុស្សស្របច្បាប់ក្នុងអំឡុងពេលនៃការបោះឆ្នោតប្រធានាធិបតី នៅខែធ្នូ ឆ្នាំ២០១០ រួមទាំងការផ្តន្ទាទោសប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស "Viasna" ដាក់ពន្ធនាគាររយៈពេលបួនឆ្នាំកន្លះ។ នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ មេធាវីលេចធ្លោម្នាក់ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ១១ឆ្នាំ ក្នុងឆ្នាំ២០១១ ហើយក្រោយមក ត្រូវបានកាត់បន្ថយមកត្រឹមជាប់ពន្ធនាគារ៦ឆ្នាំវិញ និងការហាមប្រាមលើការប្រកបវិជ្ជាជីវៈរយៈពេល១០ឆ្នាំជាមេធាវី ដោយសារ "ការឃោសនាប្រឆាំងនឹងរដ្ឋ" "ការឃុបឃិត និងការប្រមូលផ្តុំដោយមានបំណងធ្វើសកម្មភាពប្រឆាំងនឹងសន្តិសុខជាតិ" និងជា "សមាជិកនៃអ្នកការពារមជ្ឈមណ្ឌលសិទ្ធិមនុស្ស"។ ការចោទប្រកាន់នេះ ធ្វើឡើងប្រឆាំងនឹងមេធាវីសិទ្ធិមនុស្សដោយបានផ្អែកលើការសម្ភាសន៍ដែលមេធាវីរូបនេះបានធ្វើជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងកូនក្តីរបស់ខ្លួនដែលត្រូវបានដាក់ពន្ធនាគារ បន្ទាប់ពីការបោះឆ្នោតប្រធានាធិបតីនៅខែមិថុនា ឆ្នាំ២០០៩ នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់។

៥៣. សកម្មភាពដែលទាក់ទងទៅនឹងការឃ្លាំមើល និងសង្កេតការណ៍ពីការប្រព្រឹត្តទៅនៃដំណើរការបោះឆ្នោត ដោយក្រុមអន្តរជាតិ អាចស្ថិតក្រោមការរិតត្បិតដ៏ហួសហេតុផងដែរ។ នៅក្នុងបរិបទនេះ វាមានសារប្រយោជន៍ដោយរំលឹកថា ការការពារអធិបតេយ្យភាពរបស់រដ្ឋប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅមិនត្រូវបានចាត់ទុកថា ជាផលប្រយោជន៍ស្របច្បាប់តាមមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ។ អ្នករាយការណ៍ពិសេសគូសបញ្ជាក់អំពីការពិតដែលថា រដ្ឋមិនអាចសំអាងលើមូលដ្ឋានបន្ថែមទៀតបានទេ ទោះបីជារដ្ឋណាដែលច្បាប់ក្នុងស្រុករបស់ខ្លួនឱ្យធ្វើដូច្នេះ ដើម្បីដាក់កំហិតលើ

សិទ្ធិសេរីភាពខាងសមាគមក៏ដោយ។ ហេតុនេះ ការដាក់វិធានការរិតត្បិត នៅក្រោមរូបភាពបែបនេះ ដាក់កំហិតមិនត្រឹមត្រូវដល់សមាគមនៅក្នុងប្រតិបត្តិការសេរីរបស់គេ។ រដ្ឋាភិបាលដែលផាត់ចេញអ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យពីដំណើរការបោះឆ្នោត តាមរយៈការអនុម័តច្បាប់ ដូចជាចែងថា ដំណើរការនៃការចុះឈ្មោះជាបន្ទុករបស់អ្នកឃ្លាំមើលការបោះឆ្នោត ឬតាមរយៈការអញ្ជើញតែក្រុមសង្កេតការណ៍ជិតស្និទ្ធប៉ុណ្ណោះ ដែលនឹងមិនយកចិត្តទុកដាក់ខ្ពស់ក្នុងការឃ្លាំមើល នោះនឹងត្រូវធ្វើឲ្យចុះខ្សោយ ឬប្រឆាំងនឹងការរិះគន់ណាមួយ ដោយក្រុមមិនលំអៀងឯករាជ្យនោះ មិនធានាការពារសិទ្ធិសេរីភាពខាងសមាគមឡើយ។ អ្នករាយការណ៍ពិសេសទទួលស្គាល់ថាការបោះឆ្នោតបង្កើតបានជាព្រឹត្តិការណ៍យ៉ាងសំខាន់មួយនៅក្នុងជីវិតនៃប្រជាជាតិមួយ និងគួរគប្បីត្រូវបានការពារពីការជ្រៀតជ្រែកពីបរទេស។ ទោះជាយ៉ាងណាលោកទទួលស្គាល់ផងដែរពីភាពចាំបាច់ដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យច្បាស់លាស់ជាក់លាក់ និងជាសត្យានុម័ត ដែលអនុញ្ញាតឱ្យមានការសង្កេតការណ៍បោះឆ្នោតដោយឯករាជ្យ និងមិនលំអៀង ដោយអ្នកឃ្លាំមើលទាំងអស់ រួមទាំងមកពីបរទេសផង។ ក្នុងន័យនេះ ការរិតត្បិតគ្រប់ទិដ្ឋភាពលើក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ មានលក្ខណៈវិសមាមាត្រតាំងពីកំណើត ហើយដូច្នេះ ជាការរិតត្បិតមួយមិនស្របនឹងបទដ្ឋានច្បាប់អន្តរជាតិ។

**៥៤.** នៅមុនដំណើរការនៃការបោះឆ្នោត ឬបន្ទាប់ពីការបោះឆ្នោតប្រកួតប្រជែងគ្នារួចមក គឺប្រហែលជាមានករណីជាច្រើន នៃការរាំងខ្ទប់ពីរដ្ឋាភិបាល នូវការផ្តល់មូលនិធិ ដល់អង្គការសង្គមស៊ីវិល រួមទាំងអង្គការទាំងឡាយ ដែលមានអាណត្តិទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការប្រព្រឹត្តទៅនៃការបោះឆ្នោត។ឧទាហរណ៍នៅមុនដំណើរការនៃការបោះឆ្នោតនៅឆ្នាំ២០១៣ រដ្ឋាភិបាលនៃសាធារណរដ្ឋវេណេហ្ស៊ុយអេឡា បានអនុម័តច្បាប់ប្រឆាំងនឹងការផ្តល់ហិរញ្ញប្បទានចំពោះក្រុមឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងភេរវកម្ម ដែលរិតត្បិតដល់ការផ្តល់មូលនិធិទៅឲ្យ "មូលនិធិ សមាគមស៊ីវិល សមាគមមិនរកប្រាក់ចំណេញ ព្រមទាំងសមាគមដែលមានបំណងខាងនយោបាយ ឬក្រុមនៃបុគ្គលដែលឈរឈ្មោះក្នុងការបោះឆ្នោត"។ នៅក្នុងរបាយការណ៍តាមវិស័យលើកទី២របស់លោក(A/HRC/23/39) អ្នករាយការណ៍ពិសេសបានថ្លែងពីសិទ្ធិទទួលបានការផ្តល់មូលនិធិដល់អង្គការសង្គមស៊ីវិលជាផ្នែកមួយយ៉ាងសំខាន់នៃសិទ្ធិសេរីភាពខាងសមាគម។ លោកបានគូសបញ្ជាក់ថា ការដាក់កំហិតណាមួយលើលទ្ធភាពរបស់សមាគមទទួលបានមូលនិធីពីបរទេស គួរជាការចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ហើយថារដ្ឋតែងផ្តល់យុត្តិកម្មរួម ដូចជាវិធានការប្រឆាំងភេរវកម្ម ការការពារអធិបតេយ្យភាពរបស់រដ្ឋ ការបង្កើនប្រសិទ្ធភាពជំនួយ និងការកែលំអតម្លាភាព និងគណនេយ្យភាពរបស់សង្គមស៊ីវិល ជាញឹកញាប់មិនបានបំពេញតាមស្តង់ដារតឹងរឹងនោះទេ។

**៥៥.** ចំពោះករណីនៃការបញ្ឈប់ ការព្យួរ ឬការបិទសមាគមតាមទំនើងចិត្ត ដោយសារតែសកម្មភាពអនុវត្តនៅក្នុងបរិបទនៃការបោះឆ្នោត គឺជាប្រភពមួយទៀតនៃការព្រួយបារម្ភ។ នៅដើមខែមេសា ឆ្នាំ២០១២ រដ្ឋាភិបាលនៃប្រទេសស្វាស៊ីឡង់បានដកខ្លួនចេញពីសមាជសហជីពនៃប្រទេសស្វាស៊ីឡង់ និងបានប្រកាសថា សហជីពនេះខុសច្បាប់ បន្ទាប់ពីមេដឹកនាំមួយចំនួនរបស់អង្គការនេះអំពាវនាវឱ្យធ្វើពហិការចំពោះការបោះឆ្នោតឆ្នាំ២០១៣។ សេចក្ដីសម្រេចយ៉ាងតឹងតែងបែបនេះ មិនបានគោរពតាមបទដ្ឋានអន្តរជាតិ និងស្តង់ដារទាក់ទងនឹងសេរីភាពខាងសមាគមដែលបានបញ្ជាក់យ៉ាងច្បាស់ថា ការបញ្ឈប់ ការព្យួរ ឬការបិទសមាគមអាចធ្វើទៅបាន តែដោយការវិនិច្ឆ័យរបស់តុលាការតែប៉ុណ្ណោះ ដោយផ្អែកលើគ្រោះថ្នាក់ច្បាស់លាស់ និងដែលជិតកើតមាន នៅពេលដែលសមាគមប្រើប្រាស់អំពើហិង្សា ឬមានបំណងសំរេចបាននូវគោលដៅរបស់ខ្លួនដោយអំពើហិង្សា ឬដោយការញុះញង់ឱ្យមានការរើសអើង អរិភាព ឬអំពើហិង្សា ឬមានបំណងបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាពដូចបានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## V. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

*៥៦. អ្នករាយការណ៍ពិសេសមានបំណងគូសបញ្ជាក់ពីការពិតដែលថា រយៈពេលបោះឆ្នោត គឺជាឱកាសតែមួយគត់ នៅក្នុងជីវិតនៃប្រជាជាតិមួយ ដើម្បីបញ្ជាក់ និងថែមទាំងពង្រឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដូចជា ការមិនរើសអើង សមភាពយេនឌ័រ ពហុនិយមនៃទស្សនៈ និងភាពស្មើគ្នា។ លទ្ធិប្រជាធិបតេយ្យ គឺជាវិធីតែមួយ ដែលអនុញ្ញាតឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការធ្វើសេចក្ដីសម្រេច ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ លោកសង្កត់ធ្ងន់ថា រយៈពេលបោះឆ្នោត គឺជាឱកាសដ៏សំខាន់ដើម្បីកសាងស្ថាប័នប្រជាធិបតេយ្យ ដែលឆ្លើយតប និងមានគណនេយ្យភាព ហើយថារដ្ឋគួរដាក់ឱ្យអនុវត្តនូវកិច្ចការពារយ៉ាងតឹងរឹង និងច្បាស់លាស់ ដើម្បីបង្ការការជ្រៀតជ្រែកហួសហេតុនៅក្នុងវិស័យសេរីភាពសាធារណៈ ជាពិសេសគឺសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងខាងសមាគម។ លើសពីនេះទៀត អំឡុងពេលនៃការបោះឆ្នោត រដ្ឋគួរតែខិតខំប្រឹងប្រែងថែមទៀត ដើម្បីជួយសម្របសម្រួល និងការពារនូវការអនុវត្តសិទ្ធិស្នូលទាំងនេះ ដែលបុគ្គលគ្រប់រូបត្រូវទទួលបាន ជាពិសេស សមាជិកនៃក្រុមដែលប្រឈមនឹងហានិភ័យ។ តាមពិត ការបោះឆ្នោតពិតប្រាកដមិនអាចត្រូវបានសម្រេចនោះទេ ប្រសិនបើសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមត្រូវបានកាត់បន្ថយ។*

៥៧. អ្នករាយការណ៍ពិសេសមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការកើនឡើងនៃការរំលោភ និងការបំពានសិទ្ធិមនុស្ស នៅក្នុងផ្នែកជាច្រើននៃពិភពលោក ដែលបានប្រព្រឹត្តប្រឆាំងនឹងអ្នកទាំងឡាយណាដែលអនុវត្ត ឬព្យាយាមអនុវត្តសិទ្ធិសេរីភាពនៃការជួបប្រជុំគ្នាដោយសន្តិវិធី និងខាងសមាគមនៅក្នុងបរិបទនៃការបោះឆ្នោត ដែលធ្វើឲ្យខូចឈ្មោះមិនអាចលុបជ្រះដល់ការបោះឆ្នោតបែបនេះ។ នៅក្នុងស្មារតីនេះ លោកមានបំណងផ្តល់អនុសាសន៍ដូចខាងក្រោម ដែលគួរត្រូវអានរួមគ្នាជាមួយនឹងអនុសាសន៍បានដាក់រួចហើយ នៅក្នុងរបាយការណ៍តាមវិស័យចំនួន២របស់លោក ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅឆ្នាំ២០១២ (A/HRC/20/27, para 84-100) និង ឆ្នាំ២០១៣ (A/HRC/23/39, para 81-83) ដែលអនុសាសន៍មួយចំនួនដែលត្រូវបានរំលឹកឡើងវិញនៅទីនេះ។

៥៨. អ្នករាយការណ៍ពិសេសអំពាវនាវដល់រដ្ឋនានា នៅអំឡុងពេលនៃការបោះឆ្នោតឱ្យ៖

(ក) ទទួលស្គាល់ថាសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមដើរតួនាទីមិនរួញរាមួយ ក្នុងការកកើតឡើង និងអត្ថិភាពនៃប្រព័ន្ធប្រជាធិបតេយ្យដ៏មានប្រសិទ្ធភាព ដោយសារប្រព័ន្ធនេះអនុញ្ញាតឱ្យមានការសន្ទនា ពហុនិយម ការអត់ឱន និងផ្នត់គំនិតទូលំទូលាយ ដែលទស្សនៈ ឬជំនឿភាគតិច ឬជំទាស់ត្រូវបានគោរព។

(ខ) ធានាថា សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមត្រូវទទួលបានដោយបុគ្គលគ្រប់រូប អង្គភាពណាមួយទាំងបានចុះបញ្ជី ឬមិនបានចុះបញ្ជី រួមទាំងស្ត្រី អ្នកទាំងឡាយជាជនរងគ្រោះនៃការរើសអើងដោយសារតែគោលដៅផ្លូវភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ យុវជន បុគ្គលក្នុងក្រុមជនភាគតិច ជនជាតិដើមភាគតិច ជនគ្មានសញ្ជាតិ រួមទាំងជនគ្មានរដ្ឋ ជនភៀសខ្លួន ឬជនចំណាកស្រុក និងសមាជិកនៃក្រុមសាសនា ក៏ដូចជាសកម្មជនតស៊ូមតិខាងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

(គ) ធានាថា គ្មាននរណាម្នាក់ត្រូវមានទោស ចំពោះការអនុវត្តសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមនោះឡើយ ឬក៏មិនត្រូវស្ថិតក្រោមកម្មវត្ថុនៃការគំរាមកំហែង ឬការប្រើហឹង្សា ការរុកគួន ការធ្វើទុក្ខបុកម្នេញ ការបំភិតបំភ័យ ឬការសងសឹកនោះឡើយ។

(ឃ) ជួយសម្រួល និងការពារឲ្យបានខ្លាំងក្លា ដល់ការអនុវត្តសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម ហើយក្នុងន័យនេះ ត្រូវប្រុងប្រយ័ត្នខ្ពស់ជាពិសេសទាក់ទងនឹងតម្រូវការជាក់លាក់ របស់ក្រុមដែលបានលើកឡើងខាងលើ ដែលជាក្រុមប្រឈមនឹងហានិភ័យខ្ពស់ នៃការវាយប្រហារ និងការធ្វើឲ្យមានស្លាកស្នាមអាស្រូវគ្រប់ប្រភេទ។

(ង) ធានាថា ត្រូវផ្តល់ក្របខណ្ឌមួយដែលអាចឱ្យគណៈបក្សនយោបាយអាចបង្កើតបាន - ដោយមិនគិតពីមនោគមវិជ្ជានយោបាយរបស់ពួកគេ - និងសិទ្ធិទទួលបានទីលានប្រកួតប្រជែងស្មើភាព ជាពិសេសទាក់ទងនឹងលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានមូលនិធិ និងអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់ពួកគេ រួមទាំងតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី និងសិទ្ធិទទួលបានប្រព័ន្ធផ្សព្វផ្សាយ។

(ច) បង្កើនព្រំដែនសំរាប់ដាក់ការរិតត្បិតស្របច្បាប់ លើសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនិងសមាគម គឺថាត្រូវធានាពីការធ្វើតេស្តដ៏តឹងរឹងអំពីភាពចាំបាច់ និងភាពសមាមាត្រនៅក្នុងសង្គមប្រជាធិបតេយ្យ គួបផ្សំនឹងគោលការណ៍នៃការមិនរើសអើង ត្រូវបានបំពេញដោយលំបាកជាពិសេស។

(ឆ) ធានាថា ការពន្យល់ជាលាយលក្ខណ៍អក្សរលម្អិត និងទាន់ពេលវេលា សម្រាប់ការដាក់ការរិតត្បិតណាមួយ ហើយថា ការរិតត្បិតបែបនេះ អាចជាកម្មវត្ថុនៃការពិនិត្យឡើងវិញភ្លាមៗតាមផ្លូវតុលាការមួយឯករាជ្យ និងមិនលំអៀង។

(ជ) ផ្តល់ដល់បុគ្គលដែលអនុវត្តសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម នូវការការពារដែលផ្តល់ឲ្យដោយសិទ្ធិសេរីភាពនៃការបញ្ចេញមតិ។

(ឈ) ទទួលបានសិទ្ធិ និងការប្រើប្រាស់ដោយគ្មានឧបសគ្គនូវព័ត៌មាន និងបច្ចេកវិទ្យាទូរគមនាគមន៍ ដែលតាមរយៈនេះ សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមអាចអនុវត្តបាន។

(ញ) ធានាថា អ្នកទាំងឡាយណាដែលរំលោភ និង/ឬបំពានសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមរបស់បុគ្គលណាក៏ដោយ ត្រូវបានដាក់ឲ្យទទួលខុសត្រូវពេញលេញ ដោយស្ថាប័នត្រួតពិនិត្យឯករាជ្យ និងប្រជាធិបតេយ្យ និងដោយតុលាការ។

(ដ) ធានាថា ជនរងគ្រោះពីការរំលោភ និងការបំពានសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម មានសិទ្ធិទទួលបានដំណោះស្រាយទាន់ពេលវេលា និងមានប្រសិទ្ធភាព និងទទួលបានការជួសជុលសំណង។

៥៩. អ្នករាយការណ៍ពិសេសអំពាវនាវដល់ស្ថាប័នសិទ្ធិមនុស្សជាតិ ដែលស្របតាមគោលការណ៍ទីក្រុងប៉ារីស ឱ្យដើរតួនាទីសំខាន់ៗក្នុងការឃ្លាំមើល និងរាយការណ៍ជាសាធារណៈ អំពីការបំពេញតាមអនុសាសន៍ខាងលើដោយរដ្ឋ។

៦០. អ្នករាយការណ៍ពិសេសអំពាវនាវ ដល់អ្នកសង្កេតការណ៍បោះឆ្នោត ឱ្យធ្វើការគូសបញ្ជាក់ជាពិសេសអំពីការទទួលបានសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម នៅពេលសម្រេចថាតើការបោះឆ្នោតមួយពិតប្រាកដឬអត់។

៦១. អ្នករាយការណ៍ពិសេសអំពាវនាវដល់យន្តការសិទ្ធិមនុស្សអន្តរជាតិ និងតំបន់ រួមទាំងនីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញា និងការពិនិត្យតាមកាលកំណត់ជាសកល ឱ្យយកចិត្តទុកដាក់ជាក់លាក់ដល់បញ្ហានៃការបោះឆ្នោត ដោយសារថាជាបរិបទមួយ ដែលសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម ទំនងជាត្រូវបានកាត់បន្ថយ។

៦២. អ្នករាយការណ៍ពិសេស លើកទឹកចិត្តម្តងទៀត ដល់គណៈកម្មាធិការសិទ្ធិមនុស្ស ឱ្យពិចារណាអំពីការអភិវឌ្ឍសេចក្តីពន្យល់ទូទៅលើមាត្រា២១ និង២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដោយផ្តោតជាពិសេសលើការទទួលបានសិទ្ធិទាំងពីរនេះនៅក្នុងបរិបទនៃការបោះឆ្នោត។

៦៣. អ្នករាយការណ៍ពិសេសអំពាវនាវដល់មហាសន្និបាត និងក្រុមប្រឹក្សាសិទ្ធិមនុស្ស ឱ្យលើកឡើងឲ្យបានហ្មត់ចត់ពីបញ្ហានៃការរំលោភ និងការបំពានសិទ្ធិមនុស្ស នៅក្នុងបរិបទនៃការបោះឆ្នោត។

៦៤. អ្នករាយការណ៍ពិសេសអំពាវនាវដល់សហគមន៍ការទូត និងអ្នកពាក់ព័ន្ធដទៃទៀត ឱ្យថ្កោលទោសជាសាធារណៈដល់ការរំលោភបំពាន ដែលបានប្រព្រឹត្តប្រឆាំងនឹងអ្នកទាំងឡាយណា ដែលអនុវត្ត ឬព្យាយាមអនុវត្តសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគមរបស់ខ្លួន នៅក្នុងបរិបទនៃការបោះឆ្នោត និងផ្តល់ការគាំទ្រដល់ជនរងគ្រោះទាំងនេះ។